CEN
CAMBODIA EXPRESS NEWS

# រឿង សូផាត

និពន្ធដោយ

រឹម គីន


រឿង

# ប្រវត្តិរឿង សូផាត

រឿង **សូផាត** នេះអ្នកនិពន្ធ **រីម គិន** បានសរសេរតាក់តែងឡើង តាំងពី គ.ស ១៩៣៨ ប៉ុន្តែពុំទាន់បានបោះពុម្ពផ្សាយភ្លាមទេ ។ សេចក្តីលំបាក ក្នុងការផ្សាយរឿងនេះ ដោយសារពេលនោះ ពុំទាន់សំបូររោងពុម្ពនៅប្រទេស យើងនៅឡើយ ។

លុះមកដល់ គ.ស ១៩៤២ រឿង សូផាត ក៏បានផ្សាយចេញដូចបំណង នៃការប្រឹងប្រែងអ្នកនិពន្ធមែន ។ កាលនោះលោក **រីម គិន** បានសុំជំនួយជាប្រាក់ខ្លះអំពី "សមាគមន៍សិស្សចាស់នៃអនុវិទ្យាល័យ និងវិទ្យាល័យព្រះស៊ីសុវត្ថិ " ដើម្បីធ្វើជាមួយសំណៅរឿង ដែលសុំច្បាប់អនុញ្ញាតពីរាជការអាណាព្យាបាលបានហើយនោះ ទៅឱ្យរោងពុម្ពមួយនៅក្រុង ច្រឹឡឹ (ព្រៃ នគរ) ឱ្យបោះពុម្ពឱ្យ ។ ការបោះពុម្ពផ្សាយជាលើកដំបូងនោះមានចំនួន ២.០០០ច្បាប់ សឹងទទួលការនិយមយ៉ាងខ្លាំង ពីសំណាក់អ្នកមាននៅប្រទេសយើង ។ ដូច្នេះហើយបានជាសៀវភៅនេះលក់ដាច់យ៉ាងឆាប់បំផុត ហើយថែម ទាំងលេចឮសុះសាយទៅតាមមាត់អ្នកស្រុកនិទានប្រាប់គ្នាជាបន្ត១ទៅផង ។

នៅគ.ស ១៩៥០ រឿងនេះបានចូលក្នុងកម្មវិធីសិក្សាបឋមភូមិ ក៏បានបោះពុម្ពឡើងជាលើកទី២ ហើយភ្លាម១នោះមានការបោះពុម្ពជាលើកទី៣ ទី៤ បន្តមកទៀត ត្រាតែមកដល់ គ.ស ១៩៥៨ ទើបរឿងនេះទទួលបានការនិយមជាខ្លាំងក្នុងមជ្ឈដ្ឋានអ្នកសិក្សាទូទៅ ។

## ជំពូកទី១

លោក **សួន** ចៅហ្វាយស្រុក ស្រុកសិរីសោភ័ណ ជានាហ្មឺនប្រកប ដោយរូបឆោមល្អឆើតឆាយ សមសួននឹងតម្រេះវិជ្ជា លោកអាយុវទើបតែ ២៣ ឆ្នាំទេ ប៉ុន្តែលោកបានមកកាន់កាប់ស្តីទីរាជការចំនួនពីរឆ្នាំ ហើយក្នុងស្រុកសិរីសោភ័ណនេះ ។ លោកមិនបានដណ្តឹងស្រ្តីឯណាមួយធ្វើជាគូគាប់ចិត្តសោះ ប៉ុន្តែរាស្រ្តទាំងពួងដឹងជាក់ថា លោកបានទៅរួមរ័កដោយលាក់កំបាំងនឹងស្ត្រីកំព្រា ម្នាក់ឈ្មោះ នាង "**សូយ៉ា**" ចំនួនប្រាំពីរខែហើយ ។

ថ្ងៃមួយលោក **សួន** បានទទួលសំបុត្រពីរាជការធំដែលនៅភ្នំពេញ ផ្លាស់លោកទៅទីក្រុងដើម្បីទៅកាន់កាប់ទីរាជការថ្មីទៀត ។

លោក សួន គិតថា ខ្លួនអើយ ! មកនៅស្រុកនេះចំនួនពីរឆ្នាំហើយ ឃ្លាតចេញពីក្រុងភ្នំពេញ ដែលជាស្រុកកំណើតរបស់ខ្លួន ហើយដែលខ្លួនមិន ដែលបានទៅណាមកណាឃ្លាតយូរដល់ម្លេះសោះ ! អ្នកម្តាយមេម៉ាយនៅតែម្នាក់ឯង ឯរាជធានី តែងនឹករលឹកខ្លួនរាល់ថ្ងៃ ។ ការដែលរាជការតម្រូវត្រឡប់ទៅស្រុកវិញជាការប្រសើរណាស់ ។

លោកចៅហ្វាយស្រុកគិតដូច្នេះស្រេចហើយក៏មានទឹកមុខរីករាយ ។

លោក **សួន** កំពុងតែនឹកមមៃ សប្បាយចិត្តដោយបានវិលថ្កានបាន មាតាស្រាប់តែភ័ក្ត្រលោកប្រែជាស្រពោនមួយរំពេច ដោយមានគំនិតមួយចូលលុកលុយខួរក្បាលលោក "ឱ ! **សូយ៉ា** មាសបងអើយ ! នាងមានផ្ទៃពោះប្រាំខែហើយ បើបងនឹងចាកចោលនាង ដូច្នោះយល់ជាមិនសមគួរឡើយ ឥឡូវបើ នឹងយកនាងទៅជាមួយផង យល់ថាមិនកើតទេ ។ អ្នកម្តាយកាលដែលខ្លួន ចេញមកនៅស្រុកនេះបានប្តេជ្ញាថា កុំឱ្យទៅយកស្ត្រីឯណាធ្វើជាភរិយា ពីព្រោះ អ្នកបានដណ្តឹងកូនគេបញ្ជាំចិត្តទុកឱ្យហើយ ។ ព្រះអើយ ! ខ្ញុំមិនដឹងគិតយ៉ាងណាទេ ! "

លោក **សួន** យកកន្សែងតូចមួយដែលជាស្នាដៃនាង **សូយ៉ា** ជូតទឹកភ្នែកដែលហូររឹម១ លោកអញ្ជើញចូលទៅក្នុងបន្ទប់មានដំណើរធេងធោងនឹង ពន់ទុក្ខសោកនៅអាត្មា ។

វេលានោះស្ត្រីម្នាក់ចូលមក ។ នាងនោះមានរូបឆោមលោមពណ៌ល្អ ភាពជាស្រីថៃពាក់កណ្តាល ស្រីខ្មែរពាក់កណ្តាល ពោះប៉ោងបន្តិចឱ្យសម្គាល់ដឹង ថានាងមានផ្ទៃពោះ ។

លោក **សួន** ឮសូរជើងនាងដើរ ក៏ចេញពីបន្ទប់ភ្លាមស្ទុះទៅឱបនាង និយាយថា :

**សុយ៉ា** ! មាសបង ឱកម្មអ្វីរបស់យើងហ្ន៎ !

"នាង **សុយ៉ា** ភ្ញាក់ព្រើត ញ័រចំប្រប់សួរសង្សារថា :

"អ្នកបង មានរឿងអ្វី ចូរប្រាប់ប្អូនផង ? "

-ប្អូនអើយ ! បងនឹងឃ្លាតចេញពីនាង

-ពុទ្ធោ ! ....

-រាជការនឹងផ្លាស់បងទៅភ្នំពេញ ប្អូនអើយខ្លួនបងពិតមែនតែនឹងចាកចោលពៅ ប៉ុន្តែចិត្តបងប្រាកដជាចាំនៅនឹងអូនកុំកែវនាងព្រួយចិត្តពេក មិនយូរប៉ុន្មានទេគង់តែបងនឹងវិលថ្កានប្អូនស្រីវិញ បងនឹងលើកនាងឱ្យបានពេញមុខជាពុំខាន ។

-អ្នកបងអើយ ! ប្អូនសង្ឃឹមយ៉ាងមាំថា អ្នកច្បាស់ជាមិនភ្លេចពាក្យសន្យាហ្នឹងទេ ។

ទឹកមុខនាង **សុយ៉ា** ក្រៀមក្រំស្រងូតស្រងាត់ គួរឱ្យអាណិតពេកណាស់នាងផ្ដេកក្បាលទៅលើទ្រូងសង្សារ នាងខ្សឹកខ្សួលអួលអាក់ហូរធ្លាក់ទឹកនេត្រាទាំងគួរហាម ។

លោក **សួន** យកដៃមួយចាប់ភ័ក្ត្រនួននាងផ្ទាប់នឹងឱរាលោក ដៃមួយទៀតអង្អែលកេសាស្ត្រី ពោលពាក្យល្ហឹមល្ហែម "អូន ! ពាក្យសង្សារកុំកែវគិតសង្ស័យ បងស្បថឱ្យអូនបើបងដោះដៃឈប់អាល័យមិត្ត "នាង **សុយ៉ា** បានសោយសោកញញឹមស្ងួតមុខ ភ្លេចគិតដល់ពាក្យទំនៀម "ទឹកហូរមិនដែលហត់ប្រុសស្បថកុំឱ្យជឿ " ។

លោក **សួន** ដោះចិញ្ចៀនត្បូងពេជ្រពីដៃ "អូន ! ស្អែកនេះ បងនឹងឃ្លាតពីនាងហើយ ចិញ្ចៀនពេជ្រនេះ ចូរប្អូនទុកជាដំណែលរូបបងចុះបងសូម ចងជាប់នឹងចិត្តប្អូន ។ "

លោក **សួន** មានប្រសាសន៍ច្នេះហើយ ស៊កចិញ្ចៀនទៅក្នុងនាងដៃនាង **សុយ៉ា** ។

នាងរីកថ្លាមុខបន្តិច ។



## ជំពូកទី២

វិលងប៉ុន្មានខែនោះមក ក្រោយពេលដែលលោក **សួន** វិលត្រឡប់មកធ្វើការឯភ្នំពេញ នាង **សុយ៉ា** នៅតែម្នាក់ឯងឯស្រុកសិរីសោភ័ណ នាងឆ្លងទន្លេបានបុត្រប្រុសមួយរូបល្អឆើតឆាយ គួរឱ្យចេតនាពេកណាស់នៅពេលប្រកក់ឆ្អប នាងសន្មត់នាមកូននាង ហៅថា "**សុផាត**" ។

ឱ ! យើងភ្លេចនឹងនិយាយឱ្យច្បាស់លាស់ រឿងនាង **សុយ៉ា** កំព្រា

នាង **សុយ៉ា** ដូចអស់លោក អ្នកជ្រាបបន្តិចមកហើយជាស្ត្រីកំព្រាឥតមានមាតាបិតាគ្រប់គ្រងរក្សានាងទេ។ ឪពុកម្ដាយនាងពីដើមជាអ្នករកស៊ីធ្វើកសិកម្មមានទ្រព្យសម្បត្តិសមគួរ ។ កាលដែលនាង **សុយ៉ា** នៅកុមារីនៅឡើយ មានមួយឆ្នាំនោះជារដូវរាំងខ្លាំងណាស់ ។ នៅក្នុងស្រែដីគោកទាំងអស់ រកទឹកដក់បន្តិចគ្មាន ។ ស្រូវដែលស្ទូងហើយក៏ងាប់អស់ឥតសល់ ។ វេលានោះ ឪពុកនាង **សុយ៉ា** កំពុងមានជំងឺឈឺទុរន់ទុរា វេទនាគ្រូងណា។ មើលពុំបានសះ ស្បើយឡើយ ។

ហេតុតែកុសលផលកម្មសាងក្រាសពីមុនមក ឪពុកនាងក៏ទទួលអនិច្ចកម្មទៅ ។ វេលានោះ នាង **សូយ៉ា** និងមាតា កើតទុក្ខសោកសង្រេងសង្រៃអាឡោះអាល័យក្រៃពេក ស្តាយរូបបុគ្គលដែលត្រូវជាឪពុកនិងប្តី នឹងរករបស់អ្វីដែលមានតម្លៃក្រាស់ក្រៃយកមកផ្ទឹមពុំបានឡើយ ។

តាំងពីបុរសប្តីក្ស័យជីវិតទៅថ្ងៃណា អ្នកជាមាតានាង **សូយ៉ា** មិនត្រឹមតែព្រួយនឹងបុរសប្តីប៉ុណ្ណឹងទេ ថែមមកកើតទុក្ខម៉្យាងទៀត ដោយទ្រព្យសម្បត្តិក្នុងផ្ទះរលាយអស់ ព្រោះខ្លួនបានចាយវាយទិញថ្នាំសង្កូវ ថៃរោគប្តីឈឺជាប់ជាយូរខែ ។ របរដែលធ្លាប់រកបានផលទាំងប៉ុន្មានក៏ទៅជាពុំបាន ។

កើតទុក្ខនឹងខ្សត់ធនធានជាការទ្រាំបានទេ ឯកើតទុក្ខនឹងព្រាត់សង្សារ គាប់ចិត្តចេញពីខ្លួនជាទុក្ខវេទនាខ្លាំងពន់ពេកណាស់ ។ ជនដែលមានចិត្តទន់ ជួនកាលទៅជាឆ្កួតលេលាក៏មានជួនកាលទៅជាកើតទុក្ខរីងរៃលុះក្ស័យជីវិតក៏មាន ។

ឯមាតានាង **សូយ៉ា** ណាមួយព្រួយនឹងប្តី ណាមួយព្រួយនឹងបង់ធន ធានដោយមិនបានស្វែងរកព្រះធម្មសង្វេគមកដាស់តឿនចិត្តអ្នកក៏មានទុក្ខខ្លាំងពេកណាស់ទៅទៅជាឈឺ ។ គួរឱ្យអនិច្ចាដល់ **សូយ៉ា** ស្ត្រីណាស់ ! ឪពុកនាង ស្លាប់មិនទាន់បានប៉ុន្មានខែផងស្រាប់តែម្តាយនាងមានជំងឺឈឺមកទៀត ។ បើក្រៅអំពីនាងកម្រមានស្ត្រីឯណា អាយុដប់ពីរឆ្នាំ ចេះមើលថែរក្សាទ្រព្យសម្បត្តិ បីបាច់រក្សាជំងឺអ្នកមានគុណដូចនាងទេ ។ ម្តាយនាងឈឺពេញដប់ពីរខែស្រែនាង ទាំងប៉ុន្មាននាងលក់មើលរោគម្តាយអស់ ប៉ុន្តែរោគនេះពុំបានជាស្រឡះឡើយ បន្តិចឃើញថាគ្រាន់បើបន្តិចរឹតឡើងវិញ ។

ថ្ងៃមួយជំងឺឈឺរឹតតែខ្លាំងឡើង នាងមានសេចក្តីភិតភ័យជាខ្លាំងបន្តិចមកជំងឺនោះលោបែរជាស្រួលវិញ ស្រួលលើសពីដើមផង នាងមានចិត្តត្រេកអរអនេកពេក ភ្លេចគិតធៀបមើលនឹងពន្លឺភ្លើងចង្កៀងប្រេងកាតវេលាដែលនឹងអស់ប្រេង ដែលមានអណ្តាតតិច ហើយមុននឹងរលត់ស្ងាត់សូន្យបែរជាមានសន្ទុះ ភ្លឺខ្លាំងមួយភ្លែតគួរឱ្យជឿជាក់ថាលែងរលត់វិញ ។ ប៉ុន្តែសេចក្តីសង្ឃឹមនៅមិន មានយូរអង្វែងទេ ។ ចង្កៀងគ្មានប្រេង ឱ្យឆេះឯណាបាន ? ម្តាយនាង **សូយ៉ា** បន្តិចមកខ្យល់កម្មជ្ជវាត វាយជីវិតស្លាប់មួយរំពេច ។

ពុទ្ធោ ! ពុទ្ធោ ! ឱគួរឱ្យអាសូរនាង **សូយ៉ា** ណាស់ ។ នាងយំសោកបោកខ្លួនមានទុក្ខវេទនាជាខ្លាំង ។

តាំងតែអំពីថ្ងៃនោះមក នាងទៅជាកុមារីកំព្រាឥតញាតិមួយ ។

ក្រោយមកនាងចូលទៅជ្រកកោនពួនអាត្មា នៅផ្ទះអ្នកជិតខាងម្នាក់ ដែលជាអ្នកមានធមិសប្បុរស ។ លុះអាយុដប់ប្រាំពីរឆ្នាំលោកចៅហ្វាយ **សួន** បាននិយាយលួងលោមនាង លួចប្រតិព័ទ្ធដោយចិត្តនឹងចិត្ត ។ នាង **សូយ៉ា** នឹង សង្ឃឹមញញឹទុក្ខថាខ្លួនទៅមុខនឹងបានគ្រាន់បើពីព្រោះនាងជឿជាក់ពាក្យលោក **សួន** ពិរោះឈ្ងុយឆ្ងាញ់ចុកក្នុងត្រចៀកនាង ។

ស្ត្រីក្មេងល្ងង់ទាំងឡាយអើយ !

លោកអ្នកអានប្រហែលជ្រាបយល់បន្តិចហើយ រឿងនាង **សូយ៉ា** ក្រោយដែលយើងពណ៌នាយ៉ាងខ្លីមក ។ ឥឡូវយើងសូមថ្លែងតក្រោយដែល នាងសម្រាលបានកូនប្រុសរូបល្អសមសួន ។

គ្រប់តែមាតាក្នុងលោក កូនរបស់ខ្លួនជាទ្រព្យថ្លៃវិសេស ដែលមិនចង់ឱ្យរបេះឃ្លាតពីខ្លួន នាង **សូយ៉ា** ក៏ជាមាតា ដូចមាតាឯទៀតដែរ ប៉ុន្តែចិត្តស្នេហានាងលើរូបទារកច្រើនខ្លាំងលើសចិត្តមាតាឯទៀតបន្តិច ។

កូននាង គឺឪពុកនាង កូននាងគឺម្តាយនាង កូននាងគឺសង្សារនាង គឺពីព្រោះតែនាងបានកូននេះហើយ បានជានាងភ្លេចគិតពីខ្លួននាងព្រាត់ឪពុក ព្រាត់ម្តាយ ព្រាត់សង្សារ នៅឯកាអនាថាកណ្តាលលោកនេះ ។

តាំងតែគេផ្លាស់លោក **សួន** ទៅភ្នំពេញវិញ នាង **សូយ៉ា** មិនដែលបានទទួលសំបុត្រអ្វីមួយបន្ទាត់សោះ នាងក៏ទ្រាំនៅតែម្នាក់ឯងនឹងកូន ។ គាប់ជួនជាវេលាមួយស្ងាត់នាងដាក់កូនផ្តេកក្នុងអង្រឹងច្រៀងបំពេរ ។

**សូផាត** កូនអើយគេងទៅ កូនពៅអាណិតតែមាតា

ព្រួយចិត្តខ្លាំងណាស់ព្រោះឪបា ចោលម្ដាយកំព្រាតែនឹងថ្លៃ។
មិនដឹងកាលណាគេនឹកមក ឃើញមុខពន្លកកូនពិសី
បើមិនមកទេម្ដាយនឹងក្ស័យ រស់នៅធ្វើអ្វីអសោចិ៍កេរ្តិ៍។
បើមិនមកទេម្ដាយនឹងស្លាប់ ចោលប្រុសសំណាប់អ្នកមាសមេ
អាសូរកូននៅតូចម្ល៉េះទេ ធ្វើម្ដេចបុព្វេពីព្រេងនាយ ។
រស់នៅធ្វើអ្វីរស់ឥតភ័ព្វ ស៊ូស្លាប់នៅគាប់រូបរលាយ
ទុក្ខនឹងរលត់បាត់ពីម្ដាយ សមម្ដាយនឹងឆ្ងាយៗពីថ្លៃ ។
បើកុំតែម្ដាយបានប្រុសស្ងួន រម្ងាប់ផ្ទួនៗ ទុក្ខម្ដាយក្រៃ
កុំអីម្ដាយអ្នកនឹងប្រល័យ ជនឱ្យក្សិណក្ស័យឥឡូវហើយ ។
សូផាត អ្នកគេងលក់ញញឹម ញញឹមដូច្នេះទុក្ខម្ដាយស្បើយ
ញញឹមទៀតទៅពៅម្ដាយអើយ ឱកូនម្ដេចឡើយចង់យំអី ។

បាទ នៅពេលដែលនាងនិងច្រៀងបញ្ចប់ឃ្លាខាងក្រោយ ទារកដែលកំពុងដេកលក់ញញឹម ប្រែជាចង់យំវិញ ។ នាងហៀប តែនឹងលើកស្ទុះត្រកងលើកកូនបី ស្រាប់តែកូនខ្ចីលែងយំវិញ បែរជាដេកលក់ស្រមុកព្រងើយ ។ នាងយោលកូននឹកសព្វគ្រប់ទឹកភ្នែកហូរសស្រាក់ធ្លាក់មកលើកន្ទេលសញ្ជឹងសញ្ជប់ ភ្លេចស្មារតីលុះតែកូនខ្ចីស្រែកយំឡើង ។ ម្ដងនេះកូនយំមែនទែន ទើបនាងដឹងខ្លួន លើកត្រកងទារកដាក់លើដៃអង្រួនលួងលោមបន្ថែមសព្វគ្រប់ ។

ក្សិណនោះ ស្រីម្នាក់បានឡើងមកឱ្យដំណឹងនាងថា សង្សារនាង គេមានប្រពន្ធថ្មីទៀតហើយ ។ **សូយ៉ា** គ្រាន់តែឮពាក្យប៉ុណ្ណឹង ស្រែកទ្រហោយំ មួយរំពេច នាងគក់ទ្រូងផូងគ្មានប្រណី អ្នកស្ទុះឃាមរត់ក្នុងសរសៃទន់ក្បាលជង្គង់ទៅជាខ្យល់គចាប់ដួលស្រប់ភ្លាម ។

ពុទ្ធោអើយ !

នៅក្នុងលោកយើងនេះ មនុស្សមានច្រើនអ្នកណាស់ ដែលបានធ្វើបាបស្ត្រីក្រមុំស្ត្រីខ្លះក៏ទទួលកម្មដូចគ្នា ខ្លះក៏ខុសពីគ្នា ។ ប្រុសខ្លះទៅបង្ខូចកូនក្រមុំ គេគ្រាន់តែជាល្បែងបន្តិចបោះបង់គ្នាចោលចេញ ស្ត្រីនោះទៅជាអសោចិ៍កេរ្តិ៍ ត្រូវពាក្យដំនៀលគេដៀលគ្រប់មាត់ ។ មេបាបងប្អូនឈប់រាប់អាន ។ សេចក្ដីកំហឹងចូលមកដល់ ហើយដោយសារខ្លួនជាស្ត្រីខ្ចីគំនិតគិតមិនវែង ក៏បណ្ដោយខ្លួនទៅជាតែលតោល ដើរលេងសើចខូចលក្ខណ៍ ។ ខ្លះទៅជាឈឺរីងរៃ ខ្លះទៀតបំផ្លាញជីវិតបង់ ។

វេលាដែលខ្យល់គចាប់នាង **សូយ៉ា** ដួលស្រុងទៅលើព្រះធរណី អ្នកស្រុកផ្អើលឆោឡោរត់ច្រវ៉ាត់ មកជួយយកអាសានាង ខ្លះចាប់ខ្យល់ ខ្លះកោស ខ្លះឱ្យថ្នាំហិត បន្តិចមកនាងមានកម្លាំងងើបដើរបាន ។ គួរអាសូរនាងណាស់ ! ជំហានដែលនាងបោះឈានមួយៗមានដំណើរឃ្លេងឃ្លោង គន់មើលទៅមុខនាង ខ្មៅអែ ទឹកភ្នែកហូររហាម ។

-កម្មអើយ !

នាង **សូយ៉ា** តាំងតែពីថ្ងៃដែលខ្យល់ចាប់ នាងមានជំងឺមួយមកចាប់នាងជាប់គឺ ទឹកដោះនាងលែងចេញ ដៃជើងនាងហើមបរិភោគអាហារអ្វីពុំបាន ។ ចាស់ៗក្នុងភូមិដឹងរាល់គ្នាថានាងឈឺទាស់ ។

**សូផាត** កូននាង នាងឱ្យគេចិញ្ចឹមជួសនាង ។

លុះប៉ុន្មានខែក្រោយមក នាងក៏លាចាកឋានលោកយើងទៅ, អ្នកស្រុកដែលជាអ្នកមានធម៌សប្បុរស នាំគ្នាបូជាសពនាង **សូយ៉ា** ហើយទំនុកបំរុងចិញ្ចឹម **សូផាត** កូនកំព្រាបន្តិចម្នាក់ៗឡើង ។ កុមារក៏បានរស់ជន្មដោយអំណាចមេត្តាធម៌នៃសាធុជនទាំងឡាយ ។



**សូផាត** អាយុបានប្រាំបីឆ្នាំ អ្នកស្រុកគេយកទៅប្រគេនលោកក្នុងវត្ត ។ ភិក្ខុទាំងប៉ុន្មាននឹងស្រុះស្រួលគ្រប់អង្គជួយចិញ្ចឹងនឹងបង្រៀន សូផាត ពុំដែលជិនណាយវេលាណាឡើយ ។ កុមារក៏ជាក្មេងប្រកបដោយប្ញកពារិសេសជាងអស់ទាំងក្មេង ។ កិច្ចដែលបម្រើលោកទាំងប៉ុន្មាន **សូផាត** ប្រព្រឹត្តឥតឆ្គងកន្លែងណាសោះ ។ ការសិក្សារទាំងប៉ុន្មាន កុមារឧស្សាហ៍ព្យាយាមមិនចេះខ្ជិចនឿយមិនចេះខ្ជិចហត់ ។ បទគួរសមនិង ឧបាសក ឧបាសិកាចាស់ព្រឹទ្ធាចារ្យកុមារធ្វើកិរិយាឱ្យបានជាទីគាប់ចិត្តគ្រប់ៗគ្នា ។

អ្នកណាដែលបានស្គាល់លោក **សួន** តែងតែនឹកថា "ស្លឹកឈើជ្រុះមិន ដែលឆ្ងាយពីគល់ទេ" ។

**សូផាត** អាយុបានដប់ពីរឆ្នាំ ។ ថ្ងៃមួយកុមារចូលទៅជិតលោកគ្រូ ថ្វាយបង្គំរួចទើបទូលថា "ខ្ញុំព្រះករុណាចង់ទៅស្គាល់ក្រុងភ្នំពេញណាស់ ក្រែងបានឃើញមុខឪពុកព្រះករុណា ខ្ញុំព្រះករុណាសូមថ្វាយបង្គំលាព្រះតេជគុណ "។

-យី ! **សូផាត** ឯងទៅម្ដេចបាន ក្រុងភ្នំពេញធំណាស់ ឯងនឹងវង្វេងបាត់ជាមិនខាន ។

-ព្រះករុណា ខ្ញុំព្រះករុណាដឹងជាក់ច្បាស់ថា ក្រុងភ្នំពេញធំមែនហើយ ប៉ុន្តែខ្ញុំព្រះករុណាដឹងជាក់ទៀតថា ខ្ញុំព្រះករុណានឹងមិនវង្វេងទេ

លោកគ្រូ គង់ស្ងៀម គិតមួយស្របក់ ។ លោកមិនហ៊ានស្ដីបន្ទោសសិស្សលោក ដែលចចេសទៅភ្នំពេញនោះទេ ពីព្រោះលោកជ្រាបជាក់ថាគំនិត **សូផាត** ចង់ទៅភ្នំពេញនេះល្អណាស់ លោកគ្រូមានព្រះទ័យចង់ឱ្យ **សូផាត** ជួបនឹងឪពុក នឹងបានរៀនសូត្រចំណេះជ្រៅជ្រះទៅទៀត ។ លោកមិនបន្ទោស កុមារកំព្រាដែលប្រកែកថាមិនវង្វេងនោះទេ ពីព្រោះលោកបានសង្កេតប្រាជ្ញាសិស្សលោកសព្វគ្រប់ហើយ ។

-លោកមានពុទ្ធដីកាថា: អញមិនទទឹងគំនិតឯងទេ ឪពុកបាពិតមែន តែមិនបានចិញ្ចឹមបីបាច់រក្សាបាមក ប៉ុន្តែធម៌លោកសម្ដែងមកថាធម្មតាឪពុកសឹងតែមានគុណលើកូន បើដូច្នេះឯងទៅរកលោកចុះ ។ បើបាទៅដល់ក្រុងភ្នំពេញ ចូរឯងកុំភ្លេចចូលទៅវត្តឧណ្ណាលោមសិនទៅសូមជ្រកនឹងព្រះសង្ឃទំរាំបានរកឪពុកបាឃើញ ។ អញមានសម្លាញ់អញមួយអង្គនៅវត្តនោះ ព្រះនាម **ម៉ក់** ងារជាបាល័ដ្ឋ ។ មិនអីទេសឹមអញសរសេរសំបុត្រមួយឱ្យ។ នែចៅ ! អញរំពឹងមើលទៅ បើជាវេលាណាបាបានទៅជួបនឹងឪពុកបាន ឪពុកបាច្បាស់ជាឱ្យបានរៀនវិជ្ជាសំខាន់ៗអ្វី ហើយបើដូច្នេះ ចូរបាចាំស្ដាប់ពាក្យអញនឹងទូន្មានជាអវសានកាលនេះ ។

នាង ។ ឪពុកម្ដាយគឺដើមគោលគោរពនៃយើងនៅក្នុងលោកនេះអ្នកត្រូវតែគោរពលោក ដូចអ្នកគោរពព្រះពុទ្ធអង្គ ។

នាង ! ទ្រព្យដែលមានតម្លៃបំផុត គ្មានអ្វីជាជាងចំណេះទេ ចូរអ្នករកទ្រព្យនេះឱ្យបាន ។

ប្រពន្ធដែលល្អបំផុត គឺប្រពន្ធដែលស្រឡាញ់នាង កាលនាងកំពុងក្រលំបាក ។

ពាក្យអញខ្លីៗនេះ ឯងដែលមានប្រាជ្ញាវៃវាងច្រើន ល្មមគិតឃើញ វែងឆ្ងាយហើយ ។

មានព្រះពុទ្ធដីកាតែប៉ុណ្ណោះ លោកគ្រូខ្សៀកកូនសំបុត្រមួយ ទើបលោកនិមន្តទៅចាក់ទូតូចយកក្រដាសប្រាក់រៀល និងកូនកញ្ចប់តូចមួយហុចឱ្យ **សូផាត** "នាង ! នេះសំបុត្រឯងយកទៅប្រគេនលោក បាល័ដ្ឋ **ម៉ក់** នេះសោ ហ៊ុយឡាន នេះទៀតគឺ ចិញ្ចៀនកេរ្តិ៍ម្ដាយឯងទ្រព្យកេរ្តិ៍នេះ ខ្មោចម្ដាយឯងមុន នឹងស្លាប់បានផ្ដាំឱ្យឯងទុកឱ្យជាប់នឹងខ្លួន "។

កុមារទទួលសំបុត្រនឹងប្រាក់ស្រេច ទើបទទួលចិញ្ចៀនទៀត ។ **សុផាត** កាន់ចិញ្ចៀននៅដៃ នឹកមមៃដល់រូបមាតាដែលចាកស្ថានបាត់ ហើយដែលខ្លួនឥតដែលបានស្គាល់មុខសោះទើបយំង៉ក់ៗមួយរំពេច ។

លោកគ្រូដោយលោកមានសេចក្តីសង្វេតច្រើនលើរូប **សុផាត** លោកក៏ជូតទឹកព្រះនេត្រលោកដែរ ទើបមានព្រះដីការថា :

**សុផាត** ! នេះគឺកម្មរបស់ឯង ស្អែកនេះឯងទៅចុះអញឱ្យពរឯងឱ្យ បានសម្រេចដូចសេចក្តីប្រាថ្នា ។

## ជំពូកទី៣

វេលាដែលចុះអំពីរថយន្ត **សុផាត** គ្មានភ័យតក់ស្លុតនឹងទីក្រុងដែលមានផ្ទះថ្មធំៗ មានមនុស្សច្រើនពាសពេញ រទេះគ្រប់បែបរត់ច្រវាត់កាត់ទៅតាមផ្លូវទូលាយនេះទេ ។ សូផាត បើកភ្នែកធំៗជញ្ជីងសង្កេតមើលគ្រប់សព្វ រីករាយសប្បាយក្នុងចិត្តបន្តិចដើរទៅជិតមនុស្សចាស់ម្នាក់លើកដៃសំពះគេ ហើយសួរថា : លោកតា ? មេត្តាប្រាប់ខ្ញុំបន្តិច ផ្លូវណាមួយដែលតម្រង់ទៅខាងជើងកំពែងវត្តឧណ្ណាលោម ? ។

-ផ្លូវហ្នឹងហើយចៅ ចៅដើរឱ្យត្រង់ទៅទើសត្រង់ណាត្រង់ហ្នឹង ហើយវត្តឧណ្ណលោម ?

ទើបតានោះងាកមកចិញ្ចើមថ្នល់ខាងកើតចង្អុលថា "នុ៎ះនឹ ! វត្ត ឧណ្ណាលោម !"

**សុផាត** សំពះលាមនុស្សចាស់នោះស្រេច ទើបដើរតម្រង់ទៅតាមទិសដែលដៃតាចាស់ចង្អុល ។ មិនយូរប៉ុន្មានក៏បានទៅដល់ទីអារាមនោះភ្លាម ។ សូផាតក្រឡេកឃើញកុដិព្រះសង្ឃជាច្រើន ទើបរកផ្លូវក្នុងវត្ត ។ លុះដើរទៅជិតក្មេង **សុផាត** សួរថា "ប្អូន !កុដិលោកគ្រូ បាល័ដ្ឋ **ប៉ក់** នៅឯណា ? "

ក្មេងនោះធ្វើក្បាលងឹងើៗ ទើបឆ្លើយថា "ខ្ញុំមិនដែលស្គាល់លោកគ្រូ បាល័ដ្ឋ ប៉ក់ ទេ ខ្ញុំមិនដែលឮគេហៅព្រះនាមនោះផង" ។

វេលានោះ មានព្រះសង្ឃមួយអង្គចាស់ព្រះវស្សាបន្តិចមានពុទ្ធដីកា ថា "អានាង រកលោកគ្រូណា លោកគ្រូកវីវង្សា ប៉ក់ ឬ ? "

សូផាត ក្រាបថ្វាយបង្គំព្រះសង្ឃរួច ទូលតបព្រះពុទ្ធដីកាថា "ព្រះករុណាខ្ញុំព្រះករុណារកលោកគ្រូ បាល័ដ្ឋ ប៉ក់ !"

-ហ្នឹងហើយ. លោកគ្រូកវីវង្សា ប៉ក់ ពីដើមលោកធ្វើជា បាល័ដ្ឋ ។ នាងឯងមកពីស្រុកណា ឯងមិនដឹងទេឬ ? លោកគ្រូកវីវង្សា លោកសឹកយូរ ណាស់ហើយ ។

ព្រះករុណា ខ្ញុំព្រះករុណានៅក្រុងសិរីសោភ័ណ សូមព្រះករុណាមេត្តាប្រាប់ទីលំនៅលោក ឱ្យខ្ញុំព្រះករុណាបានដឹងផងបានទេ ?

-ឱនាងអើយ ! អាត្មាមិនដឹងដែរ នែ ! ចៅឯងមានការអ្វី ?

-ព្រះករុណា លោកគ្រូខ្ញុំករុណា ឱ្យខ្ញុំព្រះករុណាយកសំបុត្រនេះមកប្រគេនលោក ។

-អាត្មាបើកមើលបានទេសំបុត្រនោះ.

-ព្រះករុណា គ្មានទាស់អ្វីទេ ។

និយាយដូច្នេះហើយ **សុផាត** លុតជង្គង់លើកដៃទ្រសំបុត្រប្រគេន សំពះព្រះសង្ឃ ។

ព្រះសង្ឃទទួលសំបុត្រហែកមើលចប់ ទើបមានពុទ្ធដីកាថា "នាង អាត្មាយកអាសាចិញ្ចឹមនាងបន្តិចបាន ទំរាំនាងបានជួបនឹងឪពុកនាង ។ ឡើង មកលើកុដិមក " ។

**សុផាត** ដែលនៅសំណាក់នឹងព្រះសង្ឃមួយអង្គក្នុងវត្តឧណ្ណា លោក តែងគោរពប្រណិប័តន៍បំរើធ្វើការប្រគេនលោក ឥតចេះខ្លាចនឿយ ឥតចេះខ្លាចហត់ ឥតគិតខ្លាចថ្ងៃ ឥតគិតស្គាល់យប់ ឈប់ទំនេរវេលាណាមើលទៅត្រង់ណា ឥតទើសភ្នែកត្រង់ហ្នឹង ។ វេលានោះ អ្នកក្រាបថ្វាយបង្គំលោកលាដើរចេញមកមើលទីក្រុងស៊ើបសួររកផ្ទះលោកបាល័ដ្ឋសួន ។

គ្មានអ្នកណាស្គាល់នាហ្មឺននោះសោះ ។

ថ្ងៃមួយជាពេលសិស្សសាលាចេញពីរៀន **សុផាត** ដើរកាត់ពីភូមិបឹង វាំងមកវត្ត ស្រាប់តែឮសូរមាត់ក្មេងស្រែកទ្រហឹងអឺងកង ឃើញវាពួនចុះពួនឡើង ។ **សុផាត** កាត់យល់ជាក់ថាមានក្មេងឈ្លោះគ្នាហើយក៏ខំស្រូតរូតដល់ពពួកក្មេងនោះ ទើបស្ទុះចូលទៅក្នុងវង់ប្រដាល់ភ្លាម ដោយឃើញក្មេងម្នាក់ធំ កំពុងវាយក្មេងតូច **សុផាត** ដោយខ្លួនអ្នកមាំជាងក្មេងទាំងពីរផងបាច់ប្រឹង ប្រែងច្រើនទេនឹងឃាត់កំហឹងគេក្នុងគ្រា ។ អ្នកកំហែងឱ្យដកដៃពីក្មេងខ្សោយ ទើបអ្នកចាប់ដៃក្មេងខ្សោយឱ្យដើរទៅជិតអ្នក ហើយអ្នកជូនដំណើរត្រាដល់ផ្ទះឪពុកម្តាយ ។ កុមារតូចមានចិត្តត្រេកអរនឹង **សុផាត** ជាខ្លាំងទើបនិយាយថា "អ្នកបង ! ដែលបានជួយសង្គ្រោះខ្ញុំក្នុងគ្រា ខ្ញុំជំពាក់គុណអ្នកច្រើនណាស់ អ្នកបងមេត្តាប្រាប់ទីលំនៅអ្នកបងឱ្យប្អូនដឹងផង ខ្ញុំសូមអ្នកបងធ្វើជាសម្លាញ់ " ។

ប្អូន ! កិច្ចមនុស្សធំជួយសង្គ្រោះតូចជាកិច្ចធម្មតាទេ គឺជាការទម្លាប់ ជាប់ដុះមកក្នុងដួងចិត្តបង បងមិនគិតកម្រៃគុណស្រ័យអ្វីពីប្អូនទេ ។ ខណៈដែល សូមបងជាសម្លាញ់ បងរីករាយសប្បាយក្នុងចិត្តណាស់ ។ មនុស្សយើងដែលរស់មកប្រាថ្នាការសុខនៅក្នុងលោក តែងតែស្វែងរកឱ្យគេស្រឡាញ់រាប់អាន ។ គ្រានេះបើប្អូនសូមបងជាសម្លាញ់បងក៏សូមប្អូនជាសម្លាញ់ដែរ ។

អ្នកទាំងពីរចាប់ដៃគ្នាយ៉ាងណែន ញញឹមញញែមមើលមុខគ្នាទៅវិញទៅមក ។

ឈាមដែលរត់ក្នុងសាច់រសសៃអ្នកទាំងពីរ ហាក់ដូចជាប្រមែប្រមូល គ្នាក្នុងវេលានោះ ។

កុមារតូចដែល **សុផាត** ជួយសង្គ្រោះ "**ណារិន** " ជាក្មួយបង្កើត ប្រពន្ធលោកអធិការសេនា កំព្រាឥតឪពុកម្តាយ ហើយប្រពន្ធលោកនាហ្មឺនធំ ដែលឥតកូនយកមកចិញ្ចឹមបីបាច់ថែរក្សារ មានមេត្តាដូចជាកូនបង្កើតរបស់គេ ។

**សុផាត** និយាយថា "ប្អូនចង់ជ្រាបទីលំនៅបងឬ ? បងឥតទីលំនៅ ឪពុកម្តាយទេនៅស្រុកនេះ ម្តាយបងនៅសិរីសោភ័ណ អ្នកអនិច្ចកម្មយូរណាស់ ហើយឯបងដែលមកនៅស្រុកនេះគ្រាន់ទែមករកលោកឪពុកបង ។ ឥឡូវបងរកលោកមិនឃើញ បងនឹងគិតវិលត្រឡប់ទៅស្រុកវិញឆាប់ហើយ ។

-អ្នកបង ! ប្អូនស្រឡាញ់ចិត្តអ្នកបងណាស់ អ្នកបងកុំអាលចេញពី ប្អូនអីបើអ្នកបងពិបាកនឹងនៅវត្តលោក ខ្ញុំសូមអញ្ជើញអ្នកបងមកនៅផ្ទះខ្ញុំ ឪពុកចិញ្ចឹមខ្ញុំលោកស្រឡាញ់រាប់អានក្មេងៗណាស់ ខ្ញុំនឹងនិយាយអង្វរលោកឱ្យខាងតែលោកព្រមទទួលអ្នកបងបាន នៅជាមួយនឹងប្អូន ។

ថាតែប៉ុណ្ណោះ **ណារិន** ដឹកដៃ **សុផាត** ចូលទៅក្នុងផ្ទះ ។

លុះចូលទៅដល់ទល់មុខលោកអធិការសេនា **សុផាត** លុតជង្គង់សំ ពះសួរ **ណារិន** ជំរាបឪពុកធមិថា "លោកប៉ា ! នេះសម្លាញ់ខ្ញុំគេបានជួយសង្គ្រោះខ្ញុំពីដៃក្មេងចង្រៃមួយមាឌធំ បំណងនឹងប្រមាថមើលងាយវាយខ្ញុំ ។ សម្លាញ់ខ្ញុំនេះឥតទីលំនៅឪពុកម្តាយក្នុងក្រុងភ្នំពេញនេះទេ សព្វថ្ងៃសំណាក់នៅវត្តលោក ។ ខ្ញុំសូមអង្វរលោកប៉ាឱ្យមេត្តាករុណានេះ ព្រមទទួលឱ្យនៅជាមួយនឹងខ្ញុំបានជាគ្នាលេង ។

លោកឧកញ្ញាមើលមុខ **សុផាត** ទើបមានប្រសាសន៍ថា "ឯងឈ្មោះ អី ? ទីលំនៅ នៅស្រុកណា ?

-ខ្ញុំបាទឈ្មោះ **សុផាត** ស្រុកទេសនៅសិរីសោភ័ណ

លោកនាហ្មឺនធំជញ្ជីងរំពឹងគិតមួយស្របក់ទើបនិយាយថា "អញត្រេក អរណាស់បើឯងព្រមនៅរួមល្បែងនឹងកូនអញ "

**សុផាត** លើកដៃសំពះ នឹងគិតថា "អញមកនៅនឹងឧបាសកប្រហែល គ្រាន់បើជាងនៅនឹងព្រះសង្ឃ ដោយឥតគិតបារម្ភនឹងពាក្យគេតែងជំនៀលថា : មនុស្សខ្ជិលដេកនៅវត្តរស់ដោយសារបាយបាត្រលោក " ។

# **ជំពូកទី៤**

**សូផាត** ដែលនៅសំណាក់ក្នុងផ្ទះលោកអធិការសេនា កាន់កិរិយាមារយាទល្អត្រឹមត្រូវ បម្រើគាប់ចិត្តលោកណាស់ ។ លោកក៏ទំនុកបំរុងឱ្យរៀន សូត្រជាមួយនឹងកូនលោកដែរ ។

កុមារទាំងពីរដែលបានមកសេពគប់នឹងគ្នា យ៉ាងស្និទ្ធស្នាលដូចនេះ ក៏សម្លឹងមើលចិត្តគ្នាទៅវិញទៅមករឹងរឹតតែឆ្លុះធ្លាយខ្លាំងណាស់ទៅទៀត ។ **ណារិន** មានអស្ចារ្យនិងសម្ដីមិត្តរបស់ខ្លួន បើនឹងពោលពាក្យអ្វីសេចក្ដីសមមិនឃ្លាតឆ្ងាយពីមាត់សោះ ។ **ណារិន** ដែលធ្លាប់តែខ្ជិលច្រអូលក្នុងការរៀនសូត្រ មកកោតសរសើរសេចក្ដីព្យាយាមរបស់មិត្តខ្លួន ដែលមើលទៅឃើញមាំពេកណាស់ ។ **ណារិន** ដែលធ្លាប់តែកើតទោសនឹងគេរឿយៗតែងសរសើរ **សូផាត** ដែលចេះធ្វើឱ្យមិត្តរៀនសូត្រគ្រប់ៗគ្នាស្រឡាញ់រាប់អានទាំងអស់ គេស្រឡាញ់ដល់ទៅខ្លួន **ណារិន** ផង ។

មិនយូរប៉ុន្មាន **ណារិន** ក៏កាន់កិរិយា បានជាក្មេងល្អត្រឹមត្រូវដូច **សូផាត** ។

"សេពគប់ល្អជាកិច្ចគួរប្រតិបត្តិណាស់ "

មានមួយថ្ងៃ ជាថ្ងៃអាទិត្យ លោកអធិកាសេនាត្រូវទទួលគ្រួសារមិត្ត លោកមកកំសាន្ត នៅគេហស្ថានលោក ។ វេលាដែលចាស់កំពុងនិយាយរាក់ ទាក់លេងក្នុងបន្ទប់ទទួលភ្ញៀវក្មេងៗចំនួនបួន ប្រាំនាក់បង្កើតល្បែងលេងនៅទីសួនគ្រប់គ្នា ។

**ណារិន** មិនបានលេងនឹងគេទេ ការរបស់ខ្លួនឃាត់នៅក្នុងផ្ទះជាមួយ នឹងចាស់ៗ ។

សូផាត ដែលសក្ដិទាបជាងគេមិនហ៊ានលេងនឹងគេទេអ្នកធ្វើការរបស់ អ្នកដែលអ្នកធ្លាប់តែធ្វើគ្រប់តែថ្ងៃឈប់រៀន គឺមើលថែទាំងសួនច្បារ ។

កូនក្មេងដែលលេងទាំងប៉ុន្មានមានសម្លៀកបំពាក់ល្អៗណាស់ ។ បាវ ស្រី ប្រុស បី បួននាក់ ថែរក្សាប្រុងប្រយ័ត្នខ្លាចគ្រោះមានអ្វីមកទង្គិចកូនចៅ ហ្វាយនាយរបស់ខ្លួន ។

គួរឱ្យសប្បាយណាស់ ស័ព្ទសន្លឹកគឹកកងរំពងដែលគេលេងនោះ គេស្រែកខ្សៀវខ្សារ សើចទ្រហឹងអឹងកងរត់ច្រវាត់ទៅមក ។

**សូផាត** ឥតមានចិត្តចង់លេងនឹងគេទេ ពីព្រោះអ្នកដឹងថាខ្លួនអ្នកមិនដូចខ្លួនគេទេ ពីព្រោះអ្នកដឹងទៀតថា ពេលនេះមិនមែនជាពេលអ្នកត្រូវលេងទេ ។ អ្នកប្រឹងតែដងទឹកស្រោចដំណាំ លុះស្រោចរួចយកចបកាប់មកតម្រឹមផ្លូវបែកញើសខ្វាចចេញពីគ្រប់រោមហូរដាបពេញទាំងខ្នង ទាំងដៃ ទាំងជើង ទាំងមុខមាត់, អ្នកមិនមែនឥតសប្បាយទេ អ្នកសប្បាយនឹងឃើញករណីយកិច្ច របស់អ្នកបានបំពេញយ៉ាងគ្រប់គ្រាន់ អ្នកសប្បាយនឹងឃើញថាញើសដែលចេញ ពីសពាង្គកាយអ្នកមិនមែនចេញឥតប្រយោជន៍ទេ ។

គ្រានេះ ក្មេងម្នាក់ក្រឡេកឃើញ **សូផាត** ដែលស្លៀកក្រមារុំ សឹងតែមិនជិតពាក់កណ្ដាលខ្លួនញើសកក្បៀច គួរធុំក្លិនស្អុយ ឆ្អេះណាស់ ហើយមានភាពជាមនុស្សទាបថោក ក៏យកដុំដីដុំគ្រួសចោល **សូផាត** លេងជាល្បែងចោលរួចកេះមិត្តទាំងអស់ឱ្យមើល ។

ក្មេងទាំងអស់ទះដៃសើច ។

**សូផាត** ស្រែកប្រាប់ថា "កុំចោលខ្ញុំ ខ្ញុំឈឺណាស់ "។ ក្មេងទាំងអស់មិនព្រមស្ដាប់ រឹតតែនាំគ្នាគប់ច្រើនឡើងៗ ហើយរឹតតែទះដៃហ៊ោខ្លាំងណាស់ ទៅទៀត ។

**សូផាត** ទ្រាំមិនបាន ស្ទុះដេញកំឡាក្មេងទាំងនោះចេញ ។ និយាយ ពីបាវព្រាវបីបួននាក់លុះក្រឡេកឃើញ សូផាត ដេញកូនចៅហ្វាយរបស់ខ្លួន ក៏ព្រួតគ្នាចាប់ **សូផាត** វាយយកខ្សែមកចងបំណងនឹងនាំយកទៅជំរាបចៅហ្វាយខ្លួន ។ **សូផាត** ហើបមាត់នឹងពន្យល់ការណ៍គេ តាមដំណើរទំនងពុំបាន តែហាមាត់ភ្លាមគេទះកំភ្លៀងភ្លាម ។

បាវម្នាក់និយាយថា "អាតបនឹងកូនលោកឬ ?"

បាវម្នាក់ទៀតនិយាយថា "អាស្គាល់កូនលោកទេ ?"

ឱ ! គួរឱ្យអាសូរ **សូផាត** ណាស់ ! ឃើខ្លួនចង់ប្រាប់សេចក្តីឱ្យគេដឹង ប៉ុន្តែ គេមិនចង់ដឹងសេចក្តីពិតនោះសោះ ពីព្រោះសេចក្តីយោគយល់បុណ្យសក្តិ បង្កើតជាមោហៈដល់អ្នកឥតមេត្តាទាំងនេះទៅហើយ ។

នៅលោកនេះ មនុស្សក្រទាំងពួងច្រើនតែត្រូវគេមើលងាយ មនុស្ស តូចកើតទោសៈនិងមនុស្សធំ ។

នាង **ម៉ានយ៉ាន** កំពុងដេរនៅទីមួយ លុះក្រឡេកឃើញគេវាយ **សូផាត** ហើយចាប់ចងក៏ស្ទុះពីចម្ងាយមកស្រែកទៅបាវព្រាវទាំងអស់ថា "ឈប់សិនស្រាយចេញ ! ទោសនេះសមតែគេចងអ្នកទាំងអស់គ្នាវិញទេ គឺ យ៉ាងហ្នឹងហើយ ឬដែលគេប្រើឱ្យអ្នកឯងមើលកូនគេ ? ថាក្មេងចុះវាខូច ចំណែកអ្នកឯងចាស់ម្តេចក៏ធ្វើខូចដែរ "

បាវព្រាវទាំងអស់ខ្លាចនាង ក៏ស្រាយចំណង **សូផាត** ចេញ ។

ម្នាក់និយាយថា "នាងទាំងអស់ទេតើចោទវាមុន "

ម្នាក់ទៀត "វាបានហាមច្រើនដងដែរ "

អ្នកទីបី "វាគ្រាន់តែដេញទេ "

**សូផាត** រួចពីចំណងញញឹមដើរចេញ ។ **ម៉ានយ៉ាន** និយាយថា "បង **សូផាត** អញ្ជើញទៅងូតទឹកទៅ អ្នកណាប្រើបងឱ្យមកធ្វើសួនទាំងថ្ងៃយ៉ាងនេះ ?"

អ្នកណាមួយឈ្មោះ **ម៉ានយ៉ាន** ?

នាង **ម៉ានយ៉ាន** ជាបងស្រីបង្កើតរបស់ **ណារិន** នាងរាប់អាន សូផាតណាស់ ហើយ **សូផាត** នេះជាសម្លាញ់របស់ប្អូននាង។ ឥរិយាបទប្រព្រឹត្ត របស់ **សូផាត** ទាំងប៉ុន្មានត្រូវពេញលេញក្នុងចិត្តនាង ។

## ជំពូកទី៥

ថ្ងៃមួយ **សូផាត** និង **ណារិន** បានប្រឡងជាប់សញ្ញាប័ត្របឋម សិក្សាវិជ្ជាបារាំង ខ្មែរ ។ លោកអធិបតីសេនាមានចិត្ត ត្រេកអរជាខ្លាំង សរសើរក្មេងទាំងពីរ ចែករង្វាន់គ្រប់គ្នា ។ ណារិន និយាយទៅ សូផាត ថា អ្នកបង ! ខ្លួនខ្ញុំមិនគួរបានប្រឡងជាប់សោះ ។

-ម្តេចប្អូនថាដូច្នោះ ? ការដែលប្អូនខំរៀនរាល់ថ្ងៃនេះ សមល្អនឹងប្អូន ត្រូវប្រឡប់ជាប់ហើយ ។

-បាទទេ ប្អូនមិនចង់និយាយដូច្នេះទេ ប្អូនចង់និយាយថា តាមឬកពាពីដើមដែលធ្លាប់តែខ្ជិលច្រអូស ដើរលេងញឹកញាប់កើតទោសនឹងគេរឿយៗ នោះមិនត្រូវនឹងមានសំណាងបានប្រឡងជាប់សោះ ។

-ប្អូន ! មនុស្សយើងចូលដៃនិងអ្នកលេងទៅជាអ្នកលេង ចូលដៃនឹងអ្នកលួចទៅជាអ្នកលួច ចូលដៃនិងអ្នកខំរៀនទៅជាអ្នកខំរៀន ។ នែ ! សេចក្តីសេពគប់ជាការធំណាស់ ។

ចាប់តាំងពីថ្ងៃនោះមកកុមារទាំងពីររឹតតែស្រឡាញ់គ្នាឡើង។ លោក អធិបតីពិចារណាថា **ណារិន** វាប្រឡងជាប់ហើយ **សូផាត** ក៏ប្រឡងជាប់ដែរ ក្មេងមួយជាកូនចិញ្ចឹមជាក្មួយបង្កើត ក្មេងមួយទៀតមិនដឹងរសាត់មកពីទីណា មកទើនៅទីនេះ ។ ឥឡូវនឹងត្រូវឱ្យក្មេងទាំងពីររៀនតទៅទៀតឬ ? ចំណែក **ណារិន** ថាត្រូវតែឱ្យវារៀនទៀត ហើយចុះ **សូផាត**, ណ្ហើយឱ្យវាឈប់ត្រឹមហ្នឹងហើយ ដោយគ្នាដាច់ដោចដុនដាបម្ល៉េះ បើរការឱ្យធ្វើប្រហែលមានចិត្តត្រេកអរជាងឱ្យរៀនតទៅទៀត ។

បន្តិចអ្នកស្រីអញ្ជើញចូលមកជិតលោក បង្ហាញខោអាវប្អូនប្រាំសម្រាប់ "ខ្ញុំទើបនឹងដេរ នេះរបស់ណារិន នេះរបស់ **សុផាត** " លោកប្រុសមានប្រសាសន៍ថា "នាង ! បងត្រេកអរនឹងចិត្តនាងណាស់ លោកឈប់មួយស្របក់ ទើបមានប្រសាសន៍ថា" "នាង ! ចូរជួយពិគ្រោះបងពី **សុផាត** និង **ណារិន** បន្តិច"

-យ៉ាងដូចម្តេចអ្នកបង ?

-បងចង់ឱ្យ **ណារិន** រៀនតទៅមុខទៀត **សុផាត** បងគិតឱ្យវាឈប់ រៀន ។

-ម្តេចក៏យ៉ាងនេះ ? ខ្ញុំចង់ឱ្យវារៀនទាំងពីរនាក់ទៀត ។

-ប្អូនគិតនេះត្រូវហើយប៉ុន្តែបងយល់ថា **សុផាត** វាក្រលំបាកណាស់ បើយើងយកការឱ្យវាធ្វើ វាត្រេកអរជាងយើងឱ្យវារៀនទៅទៀត ។

អ្នកស្រីគិតមួយស្របក់ ទើបមានប្រសាសន៍ "អ្នកបងរកការឱ្យធ្វើបានភ្លាមៗទេ ។

-អូន ! គេកំពុងត្រូវការរកស្មៀនម្នាក់នៅក្នុងផ្ទះជំនួញ ។

-ខ្ញុំតាមតែអ្នកបងទេ ។

លុះបីខែក្រោយមក **ណារិន** ក៏ចូលទៅរៀនសាលា "កូលេសស៊ីសុ វត្តិ" **សុផាត** ចូលធ្វើការក្នុងការហាងជំនួញ ។

ថ្ងៃមួយ មុននឹងទៅធ្វើការ **សុផាត** ចូលទៅជំរះកាយក្នុងបន្ទប់ទឹក ។ វេលាដែលលប់លាងខ្លួន **សុផាត** ដោះចិញ្ចៀនដែលអ្នកទើបនឹងបញ្ចេញពាក់បានប៉ុន្មានថ្ងៃនេះ ទុកនៅក្បែរពាងទឹក លុះងូតទឹកស្រេចក៏ប្រញិបប្រញាប់ចេញពីបន្ទប់ទឹកភ្លាម ភ្លេចគិតដល់ចិញ្ចៀន ។ ក្រោយមកនាង ម៉ានយ៉ាន ចូលទៅក្នុងបន្ទប់នោះដែរ នាងភ្ញាក់ស្មារតីព្រើត ដោយក្រឡេកឃើញត្បូងចិញ្ចៀន ចាំងមាសភ្លឺក្រហមទែង "ចិញ្ចៀនពីណាអេះ ។ នាងរើសយកមកមើលទើបពិចារណាថា "ពេជ្រនេះល្អណាស់! មាសសុទ្ធល្អ ចិញ្ចៀនអ្នកណា ? បើរបស់អ្នក មីង ឬលោកប៉ា ម្តេចក៏អញមិនដែលឃើញ ? "

នាងកាន់ចិញ្ចៀនចេញពីបន្ទប់ទឹក ទើបឡើងលើផ្ទះលោកអធិបតី កំពុងតែងខ្លួននឹងអញ្ជើញទៅសាលា ។ នាងបង្ហាញចិញ្ចៀនទៅឪពុកធម៌ ។ លោកចាប់ចិញ្ចៀនមើល ទើបកាន់ដើរចូលទៅក្នុងបន្ទប់មួយទៅ ។ ម៉ានយ៉ានស្មានថាចិញ្ចៀនឪពុកធម៌ក៏ដើរចេញទៅ ។

និយាយពីលោកអធិបតីសេនាវិញគ្រាន់តែចូលទៅក្នុងបន្ទប់ភ្លាម លោកចាក់សោភ្លាមគួរឱ្យឆ្ងល់ណាស់ ។ មុខលោកក្រៀមមួយរំពេច ដៃទាំងពីរដាក់លើដើមទ្រូង ភ្នែករលីងរលោងសម្លឹងទៅក្រៅតាមបង្អួចមើលទៅមេឃ ហើយងាកមកក្នុងបន្ទប់វិញ ដាក់ចិញ្ចៀនទៅលើបាតដៃមានប្រសាសន៍ខ្សឹបៗល្មមតែឮម្នាក់ឯង "ឱចិញ្ចៀនអើយ ! ចិញ្ចៀននេះ គឺចិញ្ចៀនអញ ចិញ្ចៀនដែលអញឱ្យទៅ **សុយ៉ា** ឱ ! **សុយ៉ា** មាសបងអើយ ! នាងនៅទីដដែលទេឬ ? .... ហេតុម្តេចក៏ចិញ្ចៀនមករកបងឃើញ ? ខ្លួននាងម្តេចមិនឃើញ ? "

បន្តិចលោកអញ្ជើញចេញមកក្រៅ ហៅនាង **ម៉ានយ៉ាន** មកជិត ទើបសួរថា "កូនស្រី ! ឯងយកចិញ្ចៀននេះពីណាមក ? "

-ចាះ កូនរើសបានក្នុងបន្ទប់ទឹក

-កូនដឹងជាអ្នកណាយកមកទុកនៅទីនោះទេ ?

-ចាះ ទេ កូនឥតឃើញអ្នកណាម្នាក់ទេ ចិញ្ចៀននេះភ្លេចចោលនៅទី នុ៎ះ

-កូនបានឃើញអ្នកណាចូលក្នុងបន្ទប់ទឹកទេ ?

-ចាះ កាលដែលកូនចូលទៅ **សុផាត** ទើបតែចេញមក

-អរគុណហើយកូន

នាង **ម៉ានយ៉ាន** លាឪពុកចុះទៅដីលោកអធិបតិគិតថា "**សុផាត** វាជាកូនអញពិត វាថានៅសិរីសោភ័ណ គឺស្រុកប្រពន្ធអញ "

ខ្ញុំភ្លេចជំរាបអ្នកអានសៀវភៅទាំងអស់បានជ្រាប ។ លោកអធិបតី មាននាមឈ្មោះ សួន ពីដើមធ្វើបាល័ដ្ឋនៅស្រុកសិរីសោភ័ណ ទើបផ្លាស់មកភ្នំពេញវិញ ។ ដោយលោលឆ្លាតវៃច្រើនក្នុងការរាជការ លោកក៏ឆាប់បានឡើងយសសក្តិណាស់ គឺក្នុងរវាងដប់ពីរឆ្នាំ លោកបានឡើង

ពីក្រុមការជាន់កណ្តាលមកដល់ទីភូឈួយកុង្សីយ៍ ។ **សូផាត** ជាកូននាង **សូយ៉ា** សង្សារលោកពីដើម គឺកូនបង្កើតរបស់លោក ចិញ្ចៀនជាភស្តុតាងស្រាប់ ។ វេលាដែលកំពុងគិត ដូច្នោះ ចិញ្ចៀនកាន់នៅដៃ លោកស្រីអញ្ជើញចូលមកជិតលោកមានប្រសាសន៍ថា "អូន! លាក់បាំងអី **សូផាត** មិនមែនអ្នកដទៃទេវាជាកូនរបស់បង ចិញ្ចៀន បងឱ្យទៅម្តាយវាវេលាដែលបងឃ្លាតចេញមកឥឡូវនេះ វាភ្លេចចិញ្ចៀននេះនៅជិតពាងទឹក ម៉ានយ៉ាន រើសយកមកឱ្យបង បងបានដឹងដំណឹងសព្វគ្រប់ ហើយបងនឹងបណ្តុះបណ្តាលវាឱ្យសមជាកូនរបស់បងតើអូនយល់ដូចម្តេច ?

ភរិយាលោកអធិបតីសេនា ស្តាប់លោកមានប្រសាសន៍ដោយស្ងាត់ស្ងៀម ។ ក្រោយមកទើបមានវាចាថា "អ្នកបង ! កូនអ្នកបងក៏កូនខ្ញុំ ខ្ញុំមានកូនឯណាខ្ញុំ **សូផាត** នេះពីដើមមកក៏ខ្ញុំរាប់អានវាដូចជាកូនចិញ្ចឹមដែរ បើឥឡូវនេះអ្នកបងជ្រាបជាក់ថាវាជាកូនបងពិតខ្ញុំអរណាស់ហើយ យើងនាំគ្នារឹតតែស្រឡាញ់វាឡើង ។ "

លោកអធិបតីស្ទុះទៅឱបប្រពន្ធដោយត្រេកអរខ្លាំង ទើបមានប្រសាសន៍ថាអូន ! បងខ្លាចចិត្តអូនឯងណាស់ បងសូមសរសើរចិត្តអូន បងមិនស្មានថា អូនមានចិត្តដល់ប៉ុណ្ណោះទេ! "

លោកស្រីញញឹម លោកប្រុសបន្ថែមពាក្យថា "ប្រពន្ធក្រោយតែងតែ ស្អប់កូនមុនរបស់ប្តី "

-អ្នកបង ! មនុស្សស្រីស្អប់កូនមុនរបស់ប្តី ច្រើនតែស្រីនោះចិត្តអាក្រក់ ច្បាប់លោកប្រដៅថា "ប្រពន្ធគ្រប់លក្ខណ៍ មិនដែលបង្អាក់ចិត្តប្តី គិតត្រូវទេ "។ ឃើញឥតកូនមួយ ថ្វីបើ **សូផាត** ជាកូនរបស់ប្រពន្ធអ្នកបងមុន បើអ្នកបងស្រឡាញ់វាខ្ញុំក៏ស្រឡាញ់វាដែរ ។

លោកអធិបតីរីករាយ សប្បាយចិត្តជាខ្លាំង នឹងភរិយាលោកដែលមាន គំនិតល្អទើបលោកមានប្រសាសន៍ថា "អូន ! បងអរគុណនឹងឯង ហើយប៉ុន្តែឯង កុំធ្លោយរឿងនេះប្រាប់ **សូផាត** ឱ្យវាដឹងខ្លួនកុំប្រាប់អ្នកឯណាឱ្យសោះ បងនឹងធ្វើកិច្ចមួយឱ្យ **សូផាត** វាសមសក្តិជាកូនបងទៅថ្ងៃមុខ " ។

មានវាចាតែប៉ុណ្ណោះ លោកលាលោកស្រីអញ្ជើញចុះទៅធ្វើការភ្លាម ។

ពេលដែលលោកអញ្ជើញមកពីសាលាវិញ **សូផាត** ក៏ត្រឡប់មកពី ធ្វើការវិញដែរ ។

លោកអញ្ជើញចុះទៅក្រោមផ្ទះ អើតមើលទៅក្នុងបន្ទប់ សូផាត ឃើញ **សូផាត** ក៏កំពុងអង្គុយត្របោចក្បាលជង្គង់មុខក្រៀមផ្អេះ ។ លោកសួរ "**សូផាត** ឯងមានបាត់អ្វីទេ ? "

**សូផាត** ភ្ញាក់ព្រើតយកដៃមកជូតភ្នែក ទើបលើកដៃទាំងពីរសំពះជំរាបលោកថា "ព្រះបាទម្ចាស់ ខ្ញុំព្រះបាទបាត់ចិញ្ចៀនកេរ្តិ៍ពីខ្មោចម្តាយខ្ញុំបាទ "

លោកបង្ហាញចិញ្ចៀន ចិញ្ចៀនហ្នឹងឬ ?

**សូផាត** រីកមុខសំពះ "ព្រះបាទ ហ្នឹងហើយ"

លោកឱ្យចិញ្ចៀនទៅ **សូផាត** ទើបមានប្រសាសន៍ថា : បើម្តាយឯង ជាអ្នកក្រម្តេចមានចិញ្ចៀនមានតម្លៃដូច្នេះ ?

-ព្រះបាទ គឺចិញ្ចៀនកេរ្តិ៍ឪពុកខ្ញុំបាទធ្វើបាល័ដ្ឋ ។

លោកអធិបតីឈរស្ងៀម ដាក់ទឹកមុខ ទើបមានប្រសាសន៍ថា "**សូផាត** អញអាណិតឯងណាស់តាំងតែពីស្អែកនេះទៅអញចង់ឱ្យឯងទៅ រៀនតទៅទៀត តើឯងសុខចិត្តទេ ?"

-ព្រះបាទម្ចាស់ ខ្ញុំព្រះបាទតាមតែព្រះតេជគុណមេត្តាករុណាចុះ ។

-អើ ! អញនឹងឱ្យឯងទៅរៀនជាមួយនិង ណារិន ទៀត អញមិនចង់ឱ្យឯងដេកនៅក្រោមផ្ទះទេ អញមិនចង់ឱ្យឯងបរិភោគអាហារជាមួយនិងបាវព្រាវសព្វកាលទេ ។ តាំងពីថ្ងៃនេះទៅ អញឱ្យបន្ទប់ឯងមួយនៅលើផ្ទះឯង បរិភោគអាហារជាមួយនឹងអញ ជួបជុំជាមួយនឹងប្រពន្ធកូនអញទាំងអស់ ។

-ព្រះបាទ ខ្ញុំបាទមិនសមសក្តិនឹងនៅលើផ្ទះទេ បរិភោគជាមួយព្រះគុណទេ ។ កម្លាំងទានដែលព្រះតេជគុណចំណាយមកលើខ្ញុំ សព្វថ្ងៃនេះ ក្រាស់ពេកណាស់ទៅហើយ ។ ខ្ញុំព្រះបាទសូមឱ្យព្រះតេជគុណអភ័យទោស ។

**សូផាត** ! ឯងមិនត្រូវប្រកែកនឹងចិត្តសទ្ធារបស់អញទេ ។

**សូផាត** លោកដៃសំពះ មិនហ៊ានចេញវាចា ។

លោកអធិបតីអញ្ជើញឡើងទៅលើផ្ទះ ។ បន្តិច **ណារិន** និងបាវម្នាក់ ពីលើផ្ទះញញឹមញញែម។ **ណារិន** តឿន **សូផាត** ថា "លោកប៉ាឱ្យបងប្រញាប់ ជញ្ជូនឥវ៉ាន់ឡើងទៅលើផ្ទះ គេបោសជ្រះក្នុងបន្ទប់ស្រេចហើយ" ។

ទើបនិយាយទៅបាវ : ជ័យឯងជួយជញ្ជូនឥវ៉ាន់បង **សូផាត** ផង លើកហិបនេះទៅមុនទៅ !

បាវក៏ធ្វើតាមបង្គាប់ ។ វេលាដែល សូផាត កំពុងមូរកន្ទេលបត់ខោ អាវចងសៀវភៅ **ណារិន** ស្ទុះទៅស្រាយមុងប្រមូលខ្នើយ ។ បន្តិចអ្នកទាំងពីរជញ្ជូនឥវ៉ាន់ឡើងដល់ទៅលើផ្ទះ ។

**សូផាត** ភ្ញាក់ខ្លួននឹងបន្ទប់ថ្មីនៃខ្លួន ដែល **ណារិន** បង្ហាញគឺ បន្ទប់តូចច្រឡឹង បោសជ្រះស្អាតបាត មានគំនូរផ្សេងៗជាប់នឹងជញ្ជាំង គ្រែដេកតូច ល្មមមានមុងគ្របពីលើ មានពូកប្រកបដោយកម្រាលសសុទ្ធ នៅលើគ្រែមានខ្នើយឱបខ្នើយកើយ ខ្នើយគងជាប្រដាប់សម្រាប់សម្រួលកាយ ។ កូនទូតូចមួយ សម្រាប់ដាក់សម្លៀកបំពាក់ផ្អែកនៅជញ្ជាំងចុងជើង ។ កូនទូតូចមួយទៀត ដែលសម្រាប់ដាក់សៀវភៅ មានទ្វារកញ្ចក់សម្លក់មុខទៅរកទូមួយទៀត ។ កូនតុសសេរមួយ ហើយនិងកៅអីពីរនៅជាកណ្តាល ។

លោកអធិបតីចូលមក "**សូផាត** ! បន្ទប់នេះគឺបន្ទប់ឯង ការរចនាឱ្យបានរុងរឿងស្រេចនៅលើចិត្តបាស្រាប់អញរៀបប្រដាប់ឱ្យឯងឱ្យបានស្រួលបួលនេះ គឺអញទឹកសង្ឃឹមថា ឯងគង់តែនឹងបានរៀនសូត្រកើនទៅមុនទៀតពុំខាន "

លោកមានប្រសាសន៍តែប៉ុណ្ណឹង ក៏អញ្ជើញចេញទៅវិញភ្លាម ។ វេលា **ណារិន** ជួយរៀបបន្ទប់ឱ្យមិត្តស្រេច **ណារិន** ក៏លា **សូផាត** ទៅទីអគ្គាវិញទៅ។ **សូផាត** នៅតែម្នាក់ឯងសញ្ជឹងគិតថា "ខ្លួនអញអើយចំជាមានភ័ព្វមានសំណាងមែនដោយមកបានជួបនិងអ្នកមានចិត្តសប្បុរសដល់ម្លេះ : ឱ ! គេ ទំនុកបំរុងអញយ៉ាងនេះ គឺគេធ្វើឱ្យអញសប្បាយចិត្ត នឹងបានថ្លាប្រាថ្នាក្នុងការរៀនសូត្រ បើដូច្នេះគួរអញមិនត្រូវធ្វេសប្រហែសមួយវេលាឡើយ និងបំពេញកិច្ចគេ ។ សូមឱ្យគុណបុណ្យព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជួយលោកចៅហ្វាយ ខ្ញុំនេះឱ្យបានសេចក្តីសុខចំរើនគ្រប់ប្រការ ។

តាំងពីនោះមក **សូផាត** បានធូរក្នុងចិត្តជាខ្លាំង ។ សិស្សសាលា " កូលេសស៊ីសុវត្ថិ " ពីរនាក់ **សូផាត** និង **ណារិន** ជាអ្នកខំរៀនណាស់ ។ ការដែរត្រូវដាក់ឱ្យធ្វើទាំងប៉ុន្មាន អ្នកទាំងពីរធ្វើបានល្អដោយផ្សេងៗពីគ្នា ។ មេទន្ទេញគ្រប់បែបអ្នកទាំងពីរតែងចាំ ស្ទាត់មាត់តាំងពីផ្ទះរាស់ៗគ្នា ។

ពេលបរិភោគអាហារ លោកអធិការសេនាហៅ **សូផាត** ឱ្យមកជួប ជុំនិងលោកព្រមទាំងប្រពន្ធកូនលោកទាំងអស់ ។

នាង **ម៉ានយ៉ាន** ចេះតែលបសម្លឹងសញ្ជឹងក្នុងចិត្ត **សូផាត** ។ ពន្លឺ សេចក្តីស្នេហានាងលើ **សូផាត** បានពណ្ណរាយក្នុងដួងចិត្តនាង ។

ពេលហ្នឹង **ម៉ានយ៉ាន** បានអាយុដប់ប្រាំពីរឆ្នាំ **សូផាត** ដប់ប្រាំបី ។ ចូរលោកអ្នកជួយពិចារណាមើលចុះ មនុស្សភេទទីទៃពីគ្នាអាយុហៅថាកំពុងពេញ បើផ្កាហៅថាកំពុងរីក បើដើមឈើហៅថាកំពុងលូតលាស់ល្អបើមានលំនៅនៅជិតគ្នា ក្រឡេកឃើញគ្នាទៅវិញទៅមករាល់ថ្ងៃមួយសម្លឹងទៅមួយក៏ឃើញឥតឆ្គងរៀងខ្លួន នោះនឹងចាប់ចិត្តរកគ្នាទៅវិញទៅមកដាច់ជាពុំខាន ។

**សូផាត** ក៏មានគំនិតគិតគួចមេត្រី លើកល្បាណស្ត្រីដែរ ។

# ជំពូកទី៦

**សូផាត** មានរូបជាកម្លោះមួយមាឌក្រអាញមុខមូល មានឈាម ស្រស់ស្រគាំ សមសួននឹងវង្សសក្តា សម្លៀកបំពាក់មិនបានជាមានតម្លៃច្រើនទេ ប៉ុន្តែអ្នកទាំងឡាយមើលទៅត្រូវចិត្ត នឹងសម នឹងស្អាតចុះរបៀបគ្រប់បទ ។

មានស្ត្រីក្រមុំជាច្រើន ចាប់ចិត្តនឹងអ្នក ?

នាង "**អ៊ីវ៉ី**" ដែលជាកូនក្រមុំរបស់អ្នកជិតខាងមួយនៃ លោកអធិបតី សេនា មានចិត្តប្រាថ្នាលើរូប **សូផាត** ជាច្រើន ។

**សូផាត** ឥតដឹងខ្លួនបន្តិចសោះ ។

**សូផាត** បានរាប់អាននិយាយស្តីដោយសមគួរនឹងនាង **អ៊ីវ៉ី** ដែរ ។ ថ្ងៃមួយវេលាដែលនាង **អ៊ីវ៉ី** និយាយសើចលេងពីរឿងផ្សេងៗនឹង **សូផាត** នាង **អ៊ីវ៉ី** ហុចកូនកន្សែងតូចមួយទៅ **សូផាត** ទើបនិយាយថា "ខ្ញុំសូមជូនកន្សែង តូចនេះទៅបង" ។

**សូផាត** ទទួលកន្សែងធ្វើជាសង្កេតមើលសព្វគ្រប់ញញឹមជញ្ជក់មាត់ : កន្សែងនេះ ស្រឡាញ់តែជរចាក់មានថ្នាក់ល្អណាស់ បើម្លេះហើយខ្ញុំប្រយ័ត្ន មិនឱ្យបាត់ទៅណាទេ ... ។

សម្តី **សូផាត** ជាពាក្យត្រង់ពិត ប៉ុន្តែនាង **អ៊ីវ៉ី** យល់ថាជាពាក្យលែប ខាយយ៉ាងគួររបស់ប្រុសប្រសើរ ។

នាង **អ៊ីវ៉ី** ស្មានថា សូផាត ចងចិត្តនឹងនាង ។

លុះពេលយប់ស្ងាត់ នាឡិកាវាយម៉ោងដប់ពីរ នៅក្នុងភូមិស្ងាត់ឈឹង អ្នកស្រុកដែលនឿយរកស៊ីធ្វើការពីថ្ងៃ ក៏នាំគ្នាសំរាកខ្លួនពួនអាត្មា និទ្រាលក់ ស្រមុកលាន់ក្នុងផ្ទះរាប់ៗរូប នៅផ្លូវភ្លើងអគ្គិសនីព្រោងព្រាត ខ្ចាតពន្លឺចោល ទទេ ជួនកាលមានរទេះអូសមួយៗរត់យឺតៗ ដោយអ្នកអូសអស់កម្លាំងខ្លាំង ពេកណាស់ ។ ព្រះចន្ទ្ររះចិញ្ចែងចាំងរស្មីមកលើពសុធា ដើមព្រឹក្សាសឹង ស្រងាត់មានសព្វសត្វរត្តិចរទំហើយហើរទៅ ។ នៅពេលស្ងាត់ដូច្នេះ រាគតណ្ហា តែងធ្វើឱ្យងងឹតងងល់សត្វក្នុងវដ្តសង្សារ ។

ផ្ទះលោកអធិបតីសេនា មិនទាន់ស្ងាត់នៅឡើយ ។

នៅក្នុងបន្ទប់ **សូផាត** ភ្លើងផ្លុងៗចោលពន្លឺមកខាងក្រៅ ។ សិស្ស សាលា "កូលេសស៊ីសុវត្ថិ" កំពុងនាំគ្នាពីរនាក់បង្ហើយការរៀនដែលគ្រូដាក់ឱ្យ ធ្វើ ។

បន្តិច **ណារិន** លា **សូផាត** ចូលទៅបន្ទប់ដេកនៃខ្លួន **សូផាត** កំពុង តែអង្គុយច្រងូវមើលសៀវភៅតែម្នាក់ឯង លុះឮសូរជើងគេដើរព្រិប ! ព្រិប ! ក៏ស្មានថាជាដំណើរ **ណារិន** ស្រាប់តែងាកមើលឃើញរូបស្រីក្រមុំម្នាក់នៅ បង្កើយនាង អ៊ីវ៉ី ។

នាង **អ៊ីវ៉ី** ហេតុតែសេចក្តីចេតនាលើ **សូផាត** ខ្លាំងណាស់ នឹងទប់កេរ្តិ៍ ជាស្ត្រីពុំបាន ដូច្នេះហើយបានជានៅក្នុងពេលរាត្រីស្ងាត់នោះ បានឡើងទៅដល់ បន្ទប់ **សូផាត** ។

នាង **អ៊ីវ៉ី** ឈរនៅជិតតុ **សូផាត** ឥតមានវាចាអ្វី ។ **សូផាត** សួរថា "អញ្ជើញមកមានការអ្វីនៅពេលនេះ ?"

នាង **អ៊ីវ៉ី** ហាមាត់ពោលពាក្យមិនចង់រួច

-ចាំ !! ... ខ្ញុំ ...

**សូផាត** យល់ជាក់ថានាងអ៊ីវ៉ី ចាប់ចិត្តលើអ្នក ទើបនិយាយទាំងរន្ធត់ ស្លុតខ្លួន ដោយភិតភ័យនឹងម្ចាស់ផ្ទះគេដឹងរឿងហេតុ "នាង ! អញ្ជើញនាង ត្រឡប់... ទៅលំនៅនាងវិញទៅ ... ទោះបីមានការអ្វីៗស្អែកព្រឹកសឹមអញ្ជើញ មក ។

-ចាំះទេ ... ខ្ញុំមិន ... ទៅទេ ...

-ទេ !... ខ្ញុំសូមចិត្តនាង សូមនាងត្រឡប់ទៅវិញទៅ បើនាងអាណិត ខ្ញុំផ្ទះនេះមិនមែនផ្ទះខ្ញុំទេ ខ្លួនខ្ញុំមិនមែនម្ចាស់ខ្លួនខ្ញុំទេ សូមនាងអញ្ជើញទៅវិញ ទៅ !

នាង **អ៊ីវ** ដែលបានស្តាប់តែកម្លាំងចិត្តត្រេកចង់ស្នេហានាំឱ្យងងឹត គិត មិនឃើញមើលមិនយល់ការខុសត្រូវទាំងពួង ខ្ទប់មុខទទូរក្រមារចុះដីភ្លាម ។

ពេលនោះទទួលនាង **ម៉ានយ៉ាន** ដើរចេញពីក្នុងនោះមក ។ នាង **ម៉ានយ៉ាន** ធ្លាក់ថ្លើមក្តុក នឹកថា "បង **សូផាត** នេះ អញស្មានមកថា ជា មនុស្សត្រឹមត្រូវល្អ ។ តាមឫកពាដែលពុតធ្វើជាសុភាពរាបទាបនោះគួរឱ្យទុក ចិត្តល្មមផ្ញើជន្ម ផ្ញើខ្លួនប្រាណបានណាស់ ឥឡូវស្រាប់តែហ៊ានយកស្រីឡើងមក ដល់លើផ្ទះផង ! ។ ធម្មតាប្រុសយើងជាស្ត្រីសម្លឹងមិនធ្លុះដល់ក្នុងចិត្តគេទេ មិន ធ្លុះទេ" ។

**ម៉ានយ៉ាន** បិទបង្អួចយកដៃទាំងពីរគងថ្ងាសជញ្ជក់ជញ្ជឹង ប្រឹងដក ដង្ហើមធំស្តាយគំនិតដែលគិតប្រាថ្នាខុសជាយូរអង្វែងមកហើយ ។

តាំងតែពីពាក់កណ្តាលយប់ កើតកាលវិតក្កនោះមក នាង **ម៉ានយ៉ាន** ព្រួយប្រាណវេះខ្លួនចេញឆ្ងាយៗពី **សូផាត** ដរាប ។ នាងមិនដែលដើរចេញចូលក្នុងផ្ទះឱ្យបានប្រទះមុខនឹង **សូផាត** សោះបើឃើញអ្នក ប្រុសនៅត្រង់ណេះ នាងទៅត្រង់ណោះ ។ ពេលបាយនាងបរិភោគស្ងប់ស្ងាត់ វាចាខុសពីធម្មតា ដែលធីតាធ្លាប់តែនិយាយរីករាយ ដំណាលដំណើររឿងផ្សេង ៗលេងកំសាន្តទាំងអស់គ្នា ។



រំលងយូរថ្ងៃមក **សូផាត** នឹកក្នុងចិត្តថា "នាង **ម៉ានយ៉ាន** មានបើ អន់ចិត្តអ្វីនឹងអញហើយ ម្តេចក៏គេចវេះពីមុខអញម្ល៉េះ ? ម្តេចក៏នាងខ្ពើមឆ្អើម អញម្ល៉េះ ? ខ្លួនអើយដែលមកនៅក្នុងផ្ទះគេ យកចិត្តគេណាស់ មិនគួរគេគុំគួន ធ្វើស្ងើស្ងោះដូច្នេះសោះ មិនដឹងជាគេជិនឆ្អន់នឹងឯងបទណា ? ឱ ! ប្រហែលជាគេថាឯងហ៊ានប្រមាថមើលងាយលបលួចស្រឡាញ់គេហើយ ! ។ សព្វថ្ងៃដឹង ខ្លួនថាថោកទាបដែរ ប៉ុន្តែចិត្តចង្រៃឱ្យព្រួចគួចមេត្រីទៅលើគេ ខ្ញុំស្រឡាញ់គេ មិនហ៊ានឱ្យគេដឹងខ្លួនទេ ម្តេចគេនៅតែដឹងខ្លួនបាន ។ គិតទៅឃើញថា ខុស គំនិត ខ្លួនជាអ្នកកម្សត់ទុរគតិមិនគួរគួចចិត្តគិតចង់ស្ទុគ្រដល់រូបគេឡើយ មិនគួរចង់ឈោងចាប់ផ្កាយដែលនៅលើមេឃ !

សូផាត បម្រុងរត់ចេញ ។

លុះពេលព្រលប់យប់យន់បន្តិចមក **ណារិន** ទទួលមិនបានចេញមក រៀននឹង **សូផាត ខ សូផាត** ប្រដាប់ដោយខោអាវចាស់តែមួយសម្រាប់ ប្រញិបប្រញាប់ទាញសំបុត្រមួយពីហោប៉ៅ ដាក់ទៅលើតុ ស្ទុះសឹមៗចុះមកដី ដើរចេញទៅក្រៅរបងភ្លាម ! អ្នកក្រឡេកមើល ទៅផ្ទះលើកដៃពីរសំពះ ឱ គុណបុណ្យព្រះម្ចាស់ថ្លៃ ! ខ្ញុំបួងសួងសូមលោកជួយទ្រទ្រង់វង្សាលោកអធិបតី សេនា ដែលប្រកបដោយចិត្តវិសេសល្អ ។

ទឹកភ្នែកជោរចេញពេញមុខមួយរំពេច ។

**សុផាត** ឈានជើងដើរ ក្តុកក្នុងចិត្តអាឡោះអាល័យ មិនចេះអស់ មិនចេះហើយ ពីវង្សត្រកូលសារលោកអធិបតីសេនា ។ អ្នកនឹកឃើញថា លោកនា មុឺនធំមានគុណនឹងអ្នកស្មើឪពុកអ្នកបង្កើត ដោយលោកទំនុកបំរុងអ្នកសព្វគ្រប់ ស្រឡាញ់រាប់អានមិនឱ្យឃ្លើសចិត្ត លោកស្រីមិនដែលមានពាក្យបន្ទោសជេរស្តី អ្នកសោះ ។ **ណារិន** ជាមិត្តរកគ្មាននៅក្នុងលោក ។ ម៉ានយ៉ាន ជាធីតាដែល តែងតែរាប់អានអ្នកដោយស្មោះត្រង់ ។

ការខុសគឺខ្លួនអ្នកដែលក្បត់ចិត្តត្រង់របស់នាង ។

**សុផាត** ដើរកណ្តាលយប់ងងឹត មុខជ្រប់វង្វេងស្មារតីឥតវិញ្ញាណ នឹង ញ៉ាំងចិត្តអ្នកឱ្យនឹងប្រាថ្នាដើរតម្រង់ទៅទីណាឡើយ ។

## ជំពូកទី៧

លុះព្រឹកព្រហាមកាលណាឡើង ព្រះសុរិយារុងរឿងរះត្រចះត្រចង់ លើមេឃាចោលពន្លឺព្រោងព្រាតលើក្រុងភ្នំពេញ ដែលកំពុងភ្ញាក់ពីនិទ្រា មនុស្ស ម្នាដើរដេរដាសពាសពេញទាំងផ្លូវថ្នល់ រទេះគ្រប់បែបបរបើកកក្រើកដី ។ នៅ ផ្ទះលោកអធិបតីសេនាកើតចលាចលគេផ្អើលរត់រកសូផាត ដែលបាត់ទាំង កណ្តាលយប់ ។

លោកស្រីមានប្រសាសន៍ថា "ក្រែងវាចេញទៅលេងយកខ្យល់អា កាសទាំងព្រឹកទេដឹងឬ ទ្វារបើកទេតើ !"

លោកប្រុសឆ្លើយតប "វាមិនដែលដើរចេញទៅណាពីព្រលឹមទេ ! "

-បើដូច្នេះមានតែវារត់ចេញពីនេះ

-ចុះមានពីណាធ្វើវាឱ្យទាស់ចិត្ត ល្មមនឹងឱ្យវារត់ចេញពីផ្ទះយើង ?

បន្តិច **ណារិន** ស្ទុះចេញពីបន្ទប់ សូផាត មកកាន់សំបុត្រមួយនៅដៃ "លោកប៉ា ! ខ្ញុំរើសបានសំបុត្រមួយនៅក្នុងបន្ទប់សម្លាញ់ខ្ញុំ "

លោកអធិបតីមើលឃើញសរសេរនៅខ្នងសំបុត្រ "សូមជូនមកលោក អ្នកមានគុណលើខ្លួនខ្ញុំ"

លោកបើកសំបុត្រមើល :

សូមជំរាបជូនដំណឹងមកដល់លោក-អ្នក សូមទានជ្រាប ។ ពេលដែល លោក អ្នកនាង បើកសំបុត្រនេះមើល ខ្លួនខ្ញុំឃ្លាតឆ្ងាយពីនេះទៅហើយ ។ ហេតុដែលនាំឱ្យខ្ញុំបាទចាកចេញចោលទីកន្លែងលោក-អ្នក ដែលតែងតែអា ណិតអាសូរខ្ញុំ សូមលោក-អ្នកកុំគិតស្មានថា ខ្ញុំបាទតូចចិត្តអាក់អន់អ្វីនឹងលោក-អ្នកទាំងអស់ ។ លោក-អ្នក ជាឪពុកជាម្តាយចិញ្ចឹមខ្ញុំ ដែលខ្ញុំចងចិត្តគោរព រាល់យប់ថ្ងៃឥតបីសល់ពេលវេលាណា ។

ខ្លួនខ្ញុំបាទ មិនបានដឹងជារស់ឬស្លាប់ទេ សូមទានជ្រាប ណារិន ផងថា ខ្ញុំបាទបើ នឹងស្លាប់នឹងរស់ជា ចិត្តមេត្រីបានចងជាប់ក្នុងថ្លើមប្រម៉ាត់ហើយ ចំណែក **ម៉ានយ៉ាន** ដែលមានគុណលើខ្ញុំយល់ទោសកំហុសរបស់ខ្ញុំទាំងអស់ ដែលហ៊ានលបលួចមេត្រីនាង ដែលមានគុណលើខ្ញុំដែលរាប់អានខ្ញុំដោយស្មោះ ត្រង់ ។ ទោសទាំងប៉ុន្មានខ្ញុំសូមលាងឱ្យជ្រះក្នុងវេលាថ្ងៃនេះ ។ មុននឹងបញ្ចប់ សំបុត្រនេះ, ខ្ញុំសូមលើកករវន្ទាបង្គំដល់គុណបុណ្យព្រះភគវន្តមុនី សូមឱ្យលោក ជួយ លោក-អ្នកនាងទាំងអស់ ឱ្យបានសេចក្តីចំរើនគ្រប់ប្រការ ។

វេលាដែលមើលសំបុត្រចប់កាលណា លោកអធិបតីសេនាធ្លាក់សំបុត្រ ពីដៃញ័ររញ្ជក់ទាំងខ្លួន ទឹកភ្នែកហូរចេញមកមួយរំពេច រកនិយាយពាក្យអ្វីមិន ចេញ ។ លោកស្រី **ណារិន ម៉ានយ៉ាន** សឹងតែយកកន្សែងមួយម្នាក់ជូតទឹក ភ្នែករៀងខ្លួន !

-ឱ **សុផាត** អើយ !

-ឱ សម្លាញ់អើយ !

-ឱ កម្មអើយ ?

លោកប្រុសមានប្រសាសន៍ : អញឱ្យគេរក **សុផាត** ឱ្យឃើញ ! ទើប ស្រែកហៅ "អាជ័យ!"

ចៅជ័យរត់មក "ព្រះបាទ ! "

-ប្រាប់ទៅអ្នកបររទេះឡាន ឱ្យវារៀបខ្លួនជូនអញទៅក្រសួងសម្ងាត់ ។

-ព្រះបាទ

ចៅ ជ័យ រត់ចុះដីភ្លាម ។

លោកប្រុសទៅរៀបខ្លួន ទើបអញ្ជើញចុះទៅដី ។ បន្តិចឡានបើក ចេញទៅក្រៅផ្ទះ ។

លុះ ពីរ បី ម៉ោងក្រោយមក លោកអញ្ជើញ មកដល់ផ្ទះវិញ និយាយ ប្រាប់ទៅប្រពន្ធកូនវិញថា "អញឱ្យក្រសួងសម្ងាត់គេធ្វើទូរលេខទៅគ្រប់ប៉ុស្តិ៍ឱ្យ ឃាត់ដំណើរ **សុផាត** ហើយ "

លោកស្រី : សូមឱ្យគេរកឃើញទៅលោក !

**ណារិន** : ឱ្យសម្លាញ់ខ្ញុំត្រឡប់មកវិញទៅលោក !

**ម៉ានយ៉ាន** : គុណបុណ្យអើយជួយ !

គ្រួសារលោកអធិបតីសេនា ប្រុងតែស្តាប់ដំណឹងពី **សុផាត** ។ លុះ មួយអាទិត្យក្រោយមក បុគ្គលិកក្រុមព្រះនគរបាលចូលមកក្នុងផ្ទះ មកជំរាប លោកថា "រាជការទើបនឹងបានរើសខ្មោចទឹកមួយ ខ្មោចក្មេងកម្លោះអាយុ ប្រហែល ២០ ឆ្នាំ ឥតឃើញមានសំបុត្រសំគាល់អ្វីនៅខ្លួនទេ រាជការបានស្មាន ថាជាខ្មោចឈ្មោះ សូផាត រត់ចេញពីផ្ទះព្រះតេជគុណ ។

លោកអធិបតីសេនាញ័តែប៉ុណ្ណោះទន់ខ្លួនហាក់បាត់ស្មារតី ។

លោកស្រីស្រែកទ្រហោយំ ។

**ណារិន** ខ្មៅមុខអែ រត់ទៅពួនយំ ។

**ម៉ានយ៉ាន** ងងឹតមុខជ្រុប ស្ទុះទៅក្នុងបន្ទប់ ដណ្តប់ភួយទ្រហោយំ តែម្នាក់ឯង ។

បុគ្គលិកក្រុមព្រះនគរបាល លាទៅមន្ទីរគេវិញ ។

ខ្ញុំកំដរទាំងប៉ុន្មាន លុះឮដំណឹងគ្រប់គ្នា ស្ទុះមកយំទ្រហឹងអឺងកង រំពងពេញទាំងផ្ទះ ។

គួរឱ្យអាណាចអាធ័មណាស់ !

ក្រោយមកលោកអធិបតីសេនា និងគ្រួសារលោកនាំគ្នាយកខ្មោចនោះ មកធ្វើបុណ្យដុតដារកាន់ទុក្ខសព្វៗខ្លួន ។

លោកអធិបតីនិយាយទៅប្រពន្ធ "អូន ! កម្មបងអ្វីក៏ម្ល៉េះ ! ប្អូនឯង ឥតកូនមួយសោះ វេលាដែលបងបានដឹង **សុផាត** នេះជាកូនរបស់បង  បងអរ ខ្លាំងណាស់ទទួលកម្មអ្វីមកបម្រាសចេញវិញ ។ ឱ ! ស្តាយតែពុំបានធ្វើឱ្យគ្នាដឹង ខ្លួនថាបងនេះជាឪពុក។ អាណិតតែកម្សត់ត្រមោចឯកានៅស្រុកស្រែ រួចខំតាម រកបងនៅភ្នំពេញ ។

-អ្នកបងមិនគួរបិទបាំងការស្វែងរករបស់គ្នាទេ ។

-អូនអើយ ! នេះគឺបងស្រឡាញ់កូន បងមិនចង់ប្រាប់ឱ្យវាដឹងភ្លាម ថាបងនេះជាឪពុក ពីព្រោះបងមិនចង់ឱ្យវាអាងថាខ្លួនវាមានឪពុកជាអ្នកធំ អ្នក មាន ហើយបោះបង់ការរៀនសូត្រចេញ ។ បងចង់ឱ្យតែវាដឹងថា ខ្លួនវាជាកូនកំព្រា គឺកម្សត់ខ្លាំងហើយគេយកមកទំនុកបម្រុងតែនឹងប្រាប់វាដែរ នេះគឺ អកុសលរបស់វា ! ... បុណ្យកសាងមកតិចពីអតីតជាតិមក ...

-អ្នកបង លាក់បាំងអ្វីខ្ញុំបម្រុងតែនឹងផ្សំវានឹង **ម៉ានយ៉ាន**  ដែរ ។

និយាយពី **ណារិន** វិញ អ្នកកើតទុក្ខបរិភោគអ្វីសឹងតែពុំបាន ។ ពេល ដំណេកពេលរៀន អ្នកស្រមៃឃើញតែមុខសម្លាញ់អ្នក ។

ចំណែកនាង **ម៉ានយ៉ាន** នាងព្រួយប្រាណលើសអ្នកទាំងអស់ នាង គិតថា **សុផាត** លោតទឹកស្លាប់គឺពីព្រោះនាង ។ **សុផាត** ស្រឡាញ់នាងពិត គួរស្តាយរូប និងតរិយាបថអ្នកប្រុសណាស់ ។ រាល់តែថ្ងៃ រាល់តែយប់ នាងយំសោកសង្រេងសង្រៃអាល័យអាឡោះអ្នកប្រុសថ្លៃ ដែលប្រល័យខ្លួនបង់ ពី ព្រោះតែកំហុសរបស់នាង ។

រំលងយូរមក មានកូនអ្នកមានម្នាក់ឈ្មោះ **សំណាង** ចូលមកដណ្តឹង នាង **ម៉ានយ៉ាន** ។ លោកអធិបតីក៏ពុំយល់ទាស់ប្រពន្ធលោកក៏ព្រមឱ្យប៉ុន្តែ **ម៉ានយ៉ាន** និយាយអង្វរចិត្តឪពុកម្តាយចិញ្ចឹមឱ្យបង្អង់សិន ។ នាងគ្មានចិត្តគិតដល់ប្រុសដទៃក្រៅអំពីខ្មោចលង់ទឹកសោះ ។

**សំណាង** ឧស្សាហ៍ចូលមកញឹកញាយ សួរលោកអធិបតីសេនា ពី ចិត្តធីតា ។

ថ្ងៃមួយ លោកប្រុសលោកស្រី ហៅកូនមក ទើបសួរថា "កូន ! ឪពុក ម្តាយចង់ឱ្យកូនសម្រេចរឿងគេដណ្តឹងនាងឱ្យឆាប់ៗឡើងឯចិត្តឪពុកម្តាយចង់ ឱ្យតែកូនព្រមព្រាងទៅ ។ **សំណាង** ជាកូនគេអ្នកមានពូជពង្សវង្សត្រកូល ទ្រព្យសម្បត្តិគេក៏ច្រើនចំណេះវិជ្ជាគេក៏បរិបូណ៌ ចូរនាងព្រមតាមឪពុកម្តាយ ទៅ !

នាង **ម៉ានយ៉ាន** សំពះឪពុកម្តាយ ឥតមានស្តីអ្វីមួយម៉ាត់ ។

យើងអរគុណនឹងកូនព្រមតាមចិត្តយើងហើយ ។

## **ជំពូកទី៨**

ការដែលពិតនោះ **សុផាត** មិនមែនស្លាប់ទេ ខ្មោចលង់ទឹកដែលគេ រើសបានគឺមនុស្សដទៃព្រួយពីរឿងផ្សេងៗលោតទឹកសម្លាប់ខ្លួនបង់ ។ លោក អធិបតីសេនា នឹងគ្រួសារលោកទាំងអស់មើលខ្មោចនោះមិនយល់ ដោយវាហើមខ្លាំងពេកណាស់ ។

**សុផាត** ដែលរត់ចេញពីផ្ទះលោកអធិបតីសេនា ដើរតម្រង់តាមផ្លូវ កំពតទើបរត់តត្រុកតាមវាលស្រែ ចូលទៅក្នុងភូមិថ្មី ។

គឺនោះលុះដោយអារម្មណ៍នាំឱ្យព្រួយចិត្តខ្លាំង **សុផាត** ភាំងវិញ្ញាណ វល់គំនិតគិតអ្វីមិនលេច ទទួលដើរមកដល់ផ្ទះមេស្រុក **សុខ** ក៏ចូលទៅ ។

មេស្រុកសួរថា "អ្នកឯងមករកអ្វី ? "

-ខ្ញុំសូមសំណាក់នឹងលោក !

-អ្នកឈ្មោះអ្វី ? ធ្វើការរកស៊ីអ្វី ?

-បាទ ខ្ញុំបាទ ឈ្មោះ "**ផនស៊ី**" រកទទួលទានធ្វើជំនួញ ។ ក្នុងវេលា ឆ្នាំនេះ ខ្ញុំបាទជួញខាតប្រាក់អស់កើរ្តិ៍ពីឪពុកម្តាយ ។ ជាការណ៍នាំឱ្យកើតវិតក្ក ក្តុកក្តួលក្នុងចិត្តរត់ចោលស្រុក មកសូមសំណាក់នឹងលោកបណ្តោះអាសន្នសិន ។ ខ្ញុំបាទមានចំណេះវិជ្ជាបន្តិចបន្តួច នឹងសូមជួយលំហែកម្លាំងលោក ទំរាំតែខ្ញុំបាទ បានស្បើយពីទុក្ខ នឹងលាលោកត្រឡប់ទៅស្រុកវិញ ។

មេស្រុក **សុខ** មើលមុខ **ផនស៊ី** យល់ថាមានទុក្ខព្រួយមែន ទើប និយាយថា "មានអី ! ប៉ុន្តែអ្នកឯងកាន់គំនិតឱ្យត្រឹមត្រូវ "មេស្រុក **សុខ** មិន បានជឿជាក់ចិត្ត **ផនស៊ី** ទេ ។

តាំងពីថ្ងៃដែល **សូផាត** មកនៅជួយធ្វើការមេស្រុក **សុខ** មេស្រុក **សុខ** ពោលសរសើរប្រាជ្ញាថ្លារបស់ស្មៀនថ្មីមិនចេះដាច់ពីមាត់ ។ លុះរំលងយូរ បន្តិចមក មេស្រុកកាន់តែទុកចិត្តស្មៀននោះឡើង ។ វេលាស្ងាត់ មេស្រុក និយាយទៅកាន់ប្រពន្ធ "ភាណ ! ពីដើមអញស្មានថា ផនស៊ី ជាមនុស្សអាវ៉ាសែ ដែលអញព្រមឱ្យនៅជាមួយអញប្រុងតែនឹងស្ទាបចាប់រឿងអ្វីមួយ នឹងបញ្ជូនខ្លួនវាយកទៅជូនលោកចៅហ្វាយស្រុក ឥឡូវមកឃើញជាក់ថា វាជាមនុស្ស មានចំណេះវិជ្ជាច្រើន មានកិរិយាល្អឥតឃ្មើសបើនឹងនិយាយស្តីពីអ្វីៗមានពាក្យ ពិរោះណាស់ ។

-ចាំ ! ប៉ុន្តែខ្ញុំស៊ើបសួរពីស្រុកទេស មិនព្រមប្រាប់ខ្ញុំសោះ ។

-អើ ! វាមិនបាច់លាក់នឹងអញទេ អញដឹងហើយ វាមិនមែនជាអ្នក ស្រែចំការទេ ពិតជាអ្នកក្រុងសម្តីចេញមកទាំងប៉ុន្មានគឺជាសម្តីកូនអ្នកមានពូជ ។

វេលាដែលប្តីប្រពន្ធកំពុងជជែកគ្នាពីរឿងស្មៀនថ្មី ស្រាប់តែគេយក សំបុត្រមួយមកឱ្យ ។

មេស្រុកមើលសំបុត្រចប់ទើបនិយាយថា វ៉ឺយ ! លោកអធិបតីសេនា លោកអញ្ជើញមកលេងនឹងយើងក្នុងវេលាថ្ងៃស្អែក លោកស្រីកូនស្រីលោក និងអ្នកដណ្តឹងកូនស្រីលោកក៏មកដែរ គួរយើងរៀបទទួលលោកឱ្យអ៊ឹកធឹក ។

ពេលនោះ អ្នកក្លែងឈ្មោះថា **ផនស៊ី** ចូលមក ។ លោកមេស្រុក និយាយប្រាប់គ្រប់ពីដំណឹងលោកអធិបតិសេនានិងអញ្ជើញមកលេង ។

សូផាត ភ្ញាក់ខ្លួន មិនមាននិយាយស្រដីអ្វី ។

លោកមេស្រុកនិយាយទៀតថា : **ផនស៊ី** ! ម្តេចឯងនៅស្ងៀម ប្រែ ទឹកមុខយ៉ាងនេះ?

-បាទទេ ខ្ញុំវល់តែគិតវែងឆ្ងាយ ការទទួលនាម៉ឺនធំមិនជាការងាយ ទេ គោងតែគិតឱ្យច្រើន តើត្រូវមានអ្វីៗខ្លះរបៀបរៀបចំយ៉ាងដូចម្តេចខ្លះ, លោកអញ្ជើញមកលេងក្នុងស្រុកយើងម្តង គោងយើងរៀបឱ្យពេញមុខលោក ។

-ត្រូវមែនហើយ

ទើបកេះប្រពន្ធ "ឯងស្តាប់ចុះអញថាវាវៃណាស់ "

លុះស្អែកឡើង ពេលព្រលឹមនៅផ្ទះលោកមេស្រុក **សុខ** ភូមិថ្ម ប្រដាប់របៀបទទួលលោកភ្ញៀយកុង្សីយ៍រៀបហើយស្រេចមានរបៀបលំនាំ ល្អលើសលែងរបៀបមេស្រុកៗស្រែទាំងពួង ។ ទាំងមេស្រុក ទាំងកូនស្រុកសឹង សរសើរដៃអ្នករៀបចំ ...គឺ **ផនស៊ី** ។

ហេតុដូចម្តេចបានជាលោកអធិបតិអញ្ជើញមកឃុំថ្ម ?

**ខ ១**- ពីព្រោះលោកធ្លាប់រាប់អាន ស្គាល់មេស្រុង **សុខ** ជាយូរមក ហើយ ។

**ខ ២**- ពីព្រោះលោកចង់រំហែទុក្ខសោក ស្តាយកូនលោក ដែល ទទួលអនិច្ចកម្មក្នុងទឹក ។

**ខ ៣**- ពីព្រោះនាង **ម៉ានយ៉ាន** អផ្សុកកើតទុក្ខពេកណាស់ មិន ចេះអស់ចិត្តពី **សូផាត** អង្វរឪពុកឱ្យជូនមកបន្ធូបទុក្ខឯស្រុកស្រែ ។

លុះដល់ពេលលោកបិណ្ឌបាត លោកធអិបតីសេនា និងគ្រួសារ លោក អញ្ជើញមកដល់ ។ មេស្រុក **សុខ** និងរាស្ត្រជាច្រើននាក់រត់ច្រវាត់ទៅធ្វើបដិ សណ្ឋារៈរាក់ទាក់ចំពោះភ្ញៀវ ដោយសេចក្តីគួរសម ។

លោកអធិបតី ទទួលសាមគ្គី សាមគ្គា នឹងអ្នកស្រុកទាំងអស់ ទើប អញ្ជើញឡើងទៅលើផ្ទះ ។

លោកមេស្រុក **សុខ** ក្រឡេកមើលទៅក្នុងហ្វូងមនុស្សទាំងអស់ មិន ឃើញ **ផនស៊ី** ទើបសួរទៅប្រពន្ធថា ឯងឃើញ **ផនស៊ី** ទេ, ម្តេចវាមិនមក សំពះលោក

-ចាំ ខ្ញុំមិនបានឃើញវាតាំងពីព្រលឹមម្ល៉េះ

ជំទប់ **សួស** នៅជិតនោះឆ្លើយតបថា "ជំរាបលោក" **ផនស៊ី** វា ប្រាប់ខ្ញុំពីព្រលឹមថា វាមិនស្រួលខ្លួន ឥឡូវទៅសម្រាកកម្លាំងទៅហើយ ។

លោកអធិបតីសេនា សួរថា "កូនលោកមេស្រុកឬ ?

-ទានប្រោសទេ វាជាស្មៀនខ្ញុំព្រះបាទ ខ្ញុំព្រះបាទស្រឡាញ់វាដូចកូន បង្កើត ។

-ឱ្យគ្នាសម្រាកកម្លាំងទៅចុះ

**ផនស៊ី** ធ្វើពុតជាឈឺនិយាយប្រាប់ជំទប់ **សួស** គ្រាន់តែជាការងាយ គេចវេសពីទីជំនុំទេ ។

កាលណាភ្ញៀវមេស្រុក សុខ បរិភោគអាហារស្រេច អ្នកទាំងអស់គ្នា និយាយ នាំពាក្យពីការផ្សេងៗកំសាន្តលេងសប្បាយ ។ អ្នកភ្នំពេញ និយាយពី របៀបរាជការរៀបចំទីក្រុង និងប្រសាសនយោបាយក្នុងលោកសន្និវាសនេះ ។ អ្នកស្រែកនិយាយពីផលានុផល ក្នុងស្រុកនេះនិង កសិកម្មរបស់ខ្លួន និយាយពី ទឹកជំនន់ នឹងទឹកភ្លៀងក្នុងរដូវឆ្នាំថ្មី ហើយគ្មានភ្លេចសោះទេកិច្ចទាក់ទងធម្ម ជាតិទាំងឡាយ និងសាសនា ។

បន្តិចភ្ញៀវនាំគ្នាចុះពីលើផ្ទះ ដើរលេងបែកគ្នានៅជិតខាងភូមិ ។

**ម៉ានយ៉ាន** ដើរតែម្នាក់ឯង តម្រង់ទៅឯវាលស្រែ ។

នាងសប្បាយនឹងអាកាសទូលាយ ស្រែ នឹងគុម្ពស្រូវខៀវស្រងាត់ នឹង សត្វយំទំនៅគុម្ពឫស្សី ដើមត្នោតដុះត្រង់ភ្លឹងសន្ធឹងទៅលើមេឃ ត្រូវជំនោរ ខ្យល់បក់មកម្តងៗ សួរស្លឹកចាស់ៗរណ្តំគ្នាច្រាវៗ ខ្លះជ្រុះចាកដល់ដី ឯស្លឹកខ្ចីក៏ មានជ្រុះខ្លះដែរ គួរឱ្យវិវេកពេកណាស់ នឹងអាណោចអាធ័មដល់បុគ្គលដែលនៅ ជាបឋមវ័យនៅឡើយ ហើយមិនគួរនឹងមកដាច់ជីវិតសូន្យសុងក្នុងទឹកទន្លេ មេគង្គ ។

ទឹកភ្នែកស្រក់តក់ពីភ្នែកនាង ។

នាងយកកូនកន្សែងមួយទ្រាប់អង្គុយក្រោមម្លប់ត្រឈៃនៃគុម្ពឫស្សី ដៃមួយទ្រចង្កាងើយឡើងលើប្រឹងសម្លឹងមេឃ ដៃមួយទៀតនាងតោងឈើនៅ ជិតនេះហាក់ទប់អាត្មានាងកុំឱ្យអណ្តែត្រសែតតាមគំនិតនាងទៅលើអាកាសវេ ហាស៍ ដែលកល្យាណនាងមើលទៅឃើញទូលាយ ឆ្ងាយអនេកពេកពីពសុធា ដែលនាងនារីទីពឹងនៅ ...

**សំណាង** លបលួចដើរតាមនាង ។ លុះមកឃើញនាងអង្គុយស្ងប់ ស្ងាត់តែម្នាក់ឯង ក៏ម្ទីម្នាដើរទៅជិត ។

នាងភ្ញាក់ព្រើត ។

**សំណាង** និយាយ ! នាង ! ស្រុកស្រែដែលស្ងាត់យ៉ាងនេះ កោតតែ មនុស្សគេចេះរស់កើតដែរ ! បើជាបងវិញបងមិនចេះនៅស្ថិតស្ថេរចិរកាលយូរ លង់ទេ !

នាងឥតស្តីអ្វីមួយម៉ាត់ ។

សំណាង និយាយទៀតថា មើលទៅនាងហាក់អផ្សុកណាស់

-ចាំ ! ខ្ញុំសប្បាយណាស់ ។



**សំណាង** ឮពាក្យមួយម៉ាត់នេះពិរោះដូចសៀងសូរ្យតន្ត្រី ទើបប្រែសម្តីនាង ! គឺបុណ្យព្រេងយើងពីមុនមកកសាងចូលគ្នាច្រើនណាស់ ទើបជាតិ នេះយើងនិងបានជួបគ្នាជាគូគាប់ចិត្តតទៅ

**សំណាង** រង់ចាំមួយស្របក់ពុំឮនាងឆ្លើយ ទើបញញឹមប៉ប្រិម ខិត ចូលជិតនិយាយទៀតថា "អូន ! យើងនឹងបានជួបគ្នាជាគូមូលមិត្តមេត្រី បើអូនពុំយល់អ្វីសូមនាងមេត្តាឱ្យបងសូមថើបភក្ត្រនួនអ្នកយ៉ាងស្ម័គ្រស្មោះ... និយាយ ហើយក៏លោទៅ ។ នាងច្រាន "ធ្វើម្តេចដូច្នេះ ពិតមែនតែឪពុកម្តាយខ្ញុំឱ្យខ្ញុំទៅ អ្នក ប៉ុន្តែយើងមិនទាន់រៀបអាពាហ៍ពិពាហ៍នឹងគ្នាទេ យើងនៅស្រុកខ្មែរតោង តែកាន់ទំនៀមទំលាប់ខ្មែរ" ។

នាងដើរចេញ ។ សំណាង ដើរតាមដែរ ។

នាងចេញផុតពីគុម្ពឫស្សី ស្រាប់តែឃើញ **សូផាត** នៅបង្អើយជិត នោះ ។ នាងស្រែកថា "បង **សូផាត** ! បង **សូផាត** ! **សូផាត** ឈរត្រង់ខ្លួន បើកភ្នែកធំៗ ។ ដោយនាងស្មានថាជាខ្មោច **សូផាត** លង ក្បាលនាងឡើងព្រឺ នាងខ្ទប់មុខមិនហ៊ានមើលខ្មោចលង ហើយដួលស្រ៊ុបលើដី ។

**សូផាត** គេចបាត់ពីទីនោះភ្លាម ។

**សំណាង** រត់ទៅហៅអ្នកស្រុក ! ស្ទុះឆោឡោមក នាងដឹងខ្លួន និយាយពាក្យវើវវាយ "បង **សូផាត** ខ្ញុំឃើញខ្មោចបង **សូផាត** មកលងខ្ញុំ អម្បាញ់មិញ !

កាលដែលនាងក្រឡេកឃើញ **សូផាត** នាងស្មានថាជាខ្មោច សូផាត មកលងនាង ។ ដោយនាងរលឹកណាស់ភ្លាត់មាត់ហៅឈ្មោះភ្លាម ប៉ុន្តែដល់មក នឹកឃើញថាជាខ្មោច សេចក្តីខ្លាចមកពញ្ញាក់នាងឱ្យភ័យដួលមួយរំពេច ។

លោកអធិបតីសេនាមកគ្រាហ៍កូន បង្គាប់ឱ្យអ្នកស្រុកយកអង្ករ ១ ក្តាប់មកជូនលោក ទើបលោកបានហើយមានប្រសាសន៍ខ្លាំង "**សូផាត** ! បើ ឯងចាកស្ថានទៅហើយ កុំមកលេងពញ្ញាក់ប្អូនអី យកអង្ករនេះទៅ ទៅឱ្យឆ្ងាយ ពីយើងទៅ បើឃ្លានណាស់សឹមយើងសែនឱ្យស៊ី ។

ម៉ានយ៉ាន នៅតែទន្ទេញ "**សូផាត** ! **សូផាត** ! បង **សូផាត** ! "

លោកអធិបតីភ័យជាខ្លាំង បបួលប្រពន្ធកូនលោកមេស្រុក សុខ វិល ត្រឡប់ទៅភ្នំពេញវិញ ។

នៅក្នុងភូមិថ្ម គេបាត់ដំណឹងសូន្យពី **ផនស៊ី** តាំងតែពីថ្ងៃទទួលលោក នាម៉ឺនធំ ។

# ជំពូកទី៩

មកដល់ផ្ទះហើយ នាង **ម៉ានយ៉ាន** នៅតែទន្ទេញឈ្មោះ **សូផាត**  អាហារអ្វីក៏នាងមិនព្រមទទួល ពេលគេងនាងគេងមិនលក់ ។ ឪពុកម្តាយធម៌ នាង នាំនាងទៅមើលកុន ទៅមើលល្ខោន នាងនៅតែរវើរវាយ "**សូផាត** ! បងសូផាត "

លុះរៀបសែនព្រេនស្រេចជាពីរដង ជាបីដង នាងម៉ានយ៉ាននៅតែមិន ទាន់បាត់រវើរវាយ ។

-យូរបន្តិចមក ទើបនាងបានស្រាន្តខ្លួន ។

ឪពុកនាងអរជាខ្លាំង ក៏ឱ្យដំណឹងទៅឪពុក ម្តាយ **សំណាង** ។ ខាង ប្រុសជូនកំណត់វេលាការ ។

នៅថ្ងៃ ១១ រោច ក្នុងខែកត្ដិត នៅគេហស្ថានលោកអធិបតីសេនា រោងពិធីធ្វើហើយស្រេច ។ គេហៃកូនកម្លោះមកចូលរោងពីព្រលឹម ពេលល្ងាច រៀបសូត្រមន្ត រៀបលៀងភ្ញៀវ ។

ដល់មកពាក់កណ្តាលអធ្រាត្រ នាង **ម៉ានយ៉ា** មកគិតថា "សេចក្តី បំណងរបស់អញមិនឱ្យបង់បាត់ទេ"

នាងនិយាយខឹងអ្នកតែងខ្លួនម្នាក់ "បងជូនខ្ញុំទៅបត់ជើងបន្តិច ! "

-យី ! ទៅបត់ជើងឯណា ?

-ឯបង្គន់មាត់ទន្លេ ។

-ខ្ញុំមិនហ៊ានជូនទៅទេ ងងឹតណាស់ ។

-រកតែងងឹតហ្នឹងហើយ ជាការស្រួល ហើយសោះនឹងខ្មាសគេដែល នៅពាសពេញ ។

អ្នកតែងខ្លួនក៏ព្រម ។

នាងទាំងពីរចុះតាមជណ្តើរក្រោយ **ម៉ាខយ៉ាន** ប្រដាប់មានពេជ្រ ពេញទាំងខ្លួន ។

លុះដើរទៅជិតដល់បង្គប់ នាងនិយាយប្រាប់អ្នកតែងខ្លួនថា "បងនៅ ចាំខ្ញុំត្រង់ហ្នឹង ខ្ញុំដើរតែម្នាក់ឯងបានហើយ"

អ្នកតែងខ្លួនក៏ធ្វើតាមបង្គាប់ ។

នាងដើរទៅជិតបង្គន់មាត់ទន្លេ លេកីដៃទាំងពីរលើកឡើងលើ លោត ប្រួងទៅក្នុងទឹកកំពុងហូរខ្លាំងទៅសមុទ្រស្រុកចិន ។

នាង **ម៉ានយ៉ាន** សម្លាប់ខ្លួនក្នុងទឹក ដោយនាងនឹងឃើញថា **សូផាត** លោតទឹកសម្លាប់ខ្លួនដោយសារនាងនាំបង្កើតកម្មគ្រោះ ម៉្យាងទៀត នាងមិនចង់យកប្តីដែលនិងរម្ងាប់សេចក្តីអាឡោះអាល័យនាងពីប្រុសកម្សត់ កត់ចង់ចិត្តចាំនឹងនាង ។



## ជំពូកទី១០

អ្នកស្នាងខ្លួន ដែលជូននាង **ម៉ានយ៉ាន** ទៅដោះទុក្ខសត្វ លុះអង្គុយ ចាំនាងយូរពេក ក៏តាមរកមើលនាងក្នុងបង្គន់ក៏មិនឃើញ ទើបគេភ័យតក្កមារត់មកប្រាប់ឪពុកម្តាយនាង ជួបជុំនឹងភ្ញៀវគ្រប់គ្នាថា នាងពឹងឱ្យជូនទៅបង្គន់ ហើយស្រាប់តែមិនឃើញចេញពីបង្គន់មកវិញ ។

លោកអធិបតីសេនា និងញាតិកាទាំងប៉ុន្មានសង្ឃឹមថា នាងនឹងវិល ត្រឡប់មកវិញ ។ ប៉ុន្តែសេចក្តីសង្ឃឹមនេះ ខុសស្រឡះ ។ នាង ម៉ានយ៉ាន មិន ឃើញមកសោះពីបង្គន់ ។

លោកស្រីសង្ស័យណាស់ ក៏បង្គាប់មនុស្សម្នាក់ រកតាមមាត់ទន្លេ បំភ្លឺ ភ្លើងព្រោងព្រាត ។

រកមិនឃើញ ។

បន្តិចមនុស្សក្រៅ ផ្អើលឆោឡោឡើងថា សាម៉ីខ្លួនខាងស្រីរត់ទៅណា បាត់ ។ ខ្លះថា "ប្រហែលនាងមិនស្រឡាញ់ប្តីទេដឹងបានជារត់បាត់ ។ ខ្លះថា "ក្រែងខ្មោចទឹកទាញជើងទម្លាក់ក្នុងទឹកទេដឹង !"

ខ្លះឆ្លើយកាត់ថា "កុំនិយាយផ្តេសផ្តាស គេកំពុងមានមង្គលមិនដែល មានកូនគេអ្នកមានពូជពង្សបានសមសក្តិនឹងគេហើយ ម្តេចឡើយថាមិន ស្រឡាញ់ ម្យ៉ាងទៀត ខ្មោចទឹកណាហ៊ានមកទាញមនុស្ស បន្តិចទៀតគង់តែ ឃើញនាងត្រឡប់មកវិញទេ" ។

ឥតឃើញនាងមកវិញ ។

អ្នករាល់គ្នាសង្ស័យខ្លាំង នឹងនាងធ្លាក់ទឹក ។ បន្តិចអ្នកណាប្រសប់ រាវក្នុងទឹក អ្នកណាប្រសប់បង់សំណាញ់ ទាញសំណាញ់មកបង់មួយរំពេច ។

រកនាង **ម៉ានយ៉ាន** មិនឃើញ ។

ព្រឹកឡើងនៅផ្ទះលោកអធិបតីសេនា ដែលមនុស្សធ្លាប់តែពីម្សិល សើចញញឹមញញែម ដែលសប្បាយនឹងស្តាប់សព្វចម្រៀងភ្លេងលេង បទយ៉ាង ពិរោះ ស្រាប់តែស្រងូតស្រងាត់គ្រប់គ្នា ។ ងាកមើលទៅម្នាក់ធ្លាក់ទឹកមុខ ងាកមើលទៅម្នាក់ទៀតចេញទឹកភ្នែកសស្រាក់មើល ទៅម្នាក់ទៀតអង្គុយត្របោម ក្បាលជង្គង់ទឹកភ្នែករហាម ។ អ្នកទាំងអស់សុទ្ធតែប្រយុតក្នុងចិត្ត អាណិត អា ឡោះអាល័យនាង **ម៉ានយ៉ាន** ។ អ្នកស្រុកដឹងជាក់ថា **ម៉ានយ៉ាន** ស្លាប់ក្នុង ទឹក ។

**ម៉ានយ៉ាន** មិនស្លាប់ ។ វេលាដែលនាងលោតទៅក្នុងទឹកទន្លេ មាន ទូកអ្នកនេសាទត្រីម្នាក់ក៏មកដល់ ។ គេឃើញដូច្នេះ គេស្ទុះលោតទៅស្រង់នាង ភ្លាម នាងផឹកទឹកឆ្អែត សន្លប់មិនដឹងខ្លួន ។ ទើបគេប្រញាប់ប្រញាល់ឆ្លងទៅ ត្រើយម្ខាង ឯភូមិច្បារអំពៅមួយរំពេច ។

លុះអ្នកអុំទូកមកដល់ផ្ទះគេកាលណា គេស្រែកភ្លាម "សម្លាញ់អើយ ចុះមកជួយអញបន្តិច !"

បន្តិចមានប្រុសកម្លោះម្នាក់ស្ទុះចុះរហ័សពីលើផ្ទះ "មានអាសន្នអ្វី? "

-អញទៅបង់ត្រីអញឃើញព្រិល១ មនុស្សម្នាក់លោតមុជទៅក្នុង ទន្លេ អញស្រង់រើសមក ឯងជួយអញផង យើងនឹងខំជួយយកជីវិតអ្នកនោះ ។

-ស្រីឬប្រុស ?

-អញមិនដឹងជាស្រី ឬប្រុសទេងងឹងណាស់មើលអ្វីមិនយល់ទេ ។

អ្នកទាំងពីរនាំគ្នាពពីមពពើមសែងនាង **ម៉ានយ៉ាន** ឡើងលើផ្ទះ

ចង្កៀងប្រទីបតូច ចាំងពន្លឺព្រិម១ក្នុងផ្ទះ អ្នកសែងទាំងពីរឃើញ ច្បាស់ជារូបស្រី ប្រដាប់ដោយមាសពេជ្រពេញទាំងខ្លួន លាន់មាត់ទាំងពីរ "ស្រី ទេតើ"!

អ្នកនេសាទ យកចង្កៀងមកជិត មនុស្សប្រុសកម្លោះស្រាប់តែស្រែក ឡើង **ម៉ានយ៉ាន ! ម៉ានយ៉ាន !** អូនបង !

-កូនលោកអធិបតីឬ ?

-ហ្នឹងហើយ ។

នាងនៅតែមិនដឹងខ្លួន ។

អ្នកទាំងពីរលើកនាងរលាក់ឱ្យធ្លាក់ទឹក ទើបដាក់ផ្តេកវិញ ចាប់ដៃ គ្រវីចុះឡើង រកភ្លើងមកកំដៅនាង ។ បន្តិចនាងដឹងខ្លួន ។ នាងបើកភ្នែកស្រាប់ តែឃើញ **សុផាត** ទើបវាចាខ្សាវ១ "**សុផាត** ឬ "

**-ម៉ានយ៉ា** អូនបង !

-ខ្ញុំស្មានថាអ្នកបងស្លាប់បាត់យូរណាស់មកហើយ ។

-បងរស់នៅតែរាល់ថ្ងៃ ។ អញ្ជើញអូនសម្រាកកម្លាំងទៅណា កែវ ទំរាំនាងភ្ញាក់ឡើង នាងមានកម្លាំងនឹងនិយាយរឿងប្រាប់បងបន្តិច ។

នាង **ម៉ានយ៉ាន** ខំធ្មេចលក់ ដើម្បីឱ្យមានកម្លាំង

**-សុផាត** ក្រោយដែលនាង **ម៉ានយ៉ាន** ដួលសន្លប់នៅភូមិថ្ម អ្នក គេចវេះពីផ្ទះអ្នកមេស្រុក **សុខ** មកនៅភូមិច្បារអំពៅមកសូមសំណាក់នឹង សម្លាញ់អ្នកម្នាក់ឈ្មោះ " **រ៉េត** " ជាអ្នកនេសាទត្រី ពីដើមរៀនអក្សរនៅវត្ត ឧណ្ណាលោម ។ **រ៉េត** ក៏ព្រមទទួលបំបិទឈ្មោះខ្លួននៅក្នុងផ្ទះ ។ **រ៉េត** ក៏បានធ្វើ តាមមក ។

**សុផាត** និយាយាប្រាប់នាយ **រ៉េត** : ឱ បង ! នាងនេះជាកូនចិញ្ចឹម លោកអធិបតីសេនា មានគុណក្រាស់លើខ្ញុំ ពីព្រោះតែខ្ញុំស្មានខុសថា នាងស្អប់ ខ្ពើមខ្លួនខ្ញុំ បានជាខ្ញុំរត់ចេញពីផ្ទះលោកអធិបតីមក នាងប្រាកដជាមានចិត្តបេតី លើខ្ញុំ ។ រឿងនេះនៅភូមិថ្មជាភស្តុតាងស្រាប់ ។

-ប្អូនអើយ ! រឿងមនុស្សស្រីហើយនឹងមនុស្សប្រុសចងចិត្តនឹងគ្នា ហើយមិនដឹងតែសព្វខ្លួន មានច្រើនណាស់ !

បន្តិចនាង ម៉ានយ៉ាន បើកភ្នែកភ្ញាក់ !

**សុផាត** និយាយ : អូនគេងបន្តិចទៅណា ! ។

-ចាំ ខ្ញុំមានកម្លាំងណាស់ហើយ ។

**សុផាត** ស្ទុះទៅដួសបបរដែលខ្លួនដាំទុក ទៅយកផ្លែឈើ :

"អូនអញ្ជើញញ៉ាំបបរ ចេក !"

**ម៉ានយ៉ាន** ញញឹមអញ្ជើញ **សូផាត** ឱ្យបរិភោគជាមួយនឹងនាង សូផាតក៏ធ្វើតាមបង្គាប់ ។ លុះបរិភោគស្រេច **សូផាត** សួរនាងថា "អូន ! ហេតុអ្វីក៏នាងមកលង់ទឹកដូច្នេះ" **ម៉ានយ៉ាន** មិនស្រដី ទើបសួរវិញថា "ហេតុ អ្វី ក៏អ្នកបងរត់ចេញពីផ្ទះលោកឪពុកខ្ញុំ "

-ប្អូន ! បងនិយាយប្រាប់ប្អូនឱ្យអស់ទៅចុះ បងស្មានមកថានាងស្អប់ ខ្ពើមលើរូបបងណាស់ មិនដឹងជាហេតុអ្វី ស្រាប់តែអូនគេចវេះពីមុខបង លែង និយាយលេងនឹងបង បងតូចចិត្តនឹងខ្លួនបងដែលជាអ្នកខ្សត់ខ្សោយ ហើយហ៊ាន លួចមេត្រីលើនាង ។

-ឱ អ្នកបង ! នាងណាមួយដែលចេញពីបន្ទប់អ្នកបងមក ក្នុងវេលា ម៉ោងមួយភ្លឺយប់ថ្ងៃ១៤ កើត ខែចេត្រ ។

សូផាត នឹកឃើញៈ អូន ! ក្នុងវេលាយប់នោះ នាង **អុីវ** ចូលក្នុងបន្ទប់ បង បងអង្វរឱ្យចេញទៅវិញ ។

ម៉ានយ៉ាន ញញឹម : តែស្វានិងចេក ក្អែកនិងពងមាន់ ។

-ប្អូន ! បងលើកដៃមួយឡើង ! ( សូផាត លើកដៃស្តាំស្បថ ) ចិត្ត មេត្រីរបស់បងមានតែរូបអូនមួយពិត ។

**ម៉ានយ៉ាន** ស្រក់ទឹកភ្នែក **សូផាត** ស្ទុះយកកូនកន្សែងមួយមកជូត ឱ្យនាងទើបនិយាយថា "អ្នកបងក្រោយដែលអ្នកបងចាកចេញពីផ្ទះខ្ញុំមក មាន គេរើសបានខ្មោចមួយ អ្នកទាំងអស់គ្នាស្មានថាជាខ្មោចអ្នកបង បានទាំងយក ខ្មោចនោះមកដុតដារផង ក្រោយមកទៀតឪពុកខ្ញុំឱ្យខ្ញុំទៅ **សំណាង** ដែលខ្ញុំ ឥតចិត្តគិតមេត្រីសោះ វេលាដែលរៀបការខ្ញុំ បម្រុងតែបំផ្លាញជីវិតបង់ក្នុងទឹក ទន្លេតាមអ្នកបង ដែលខ្ញុំស្មានថាជា លោតទឹកស្លាប់យូរមកហើយ ដោយសារ ប្អូន ។

**សូផាត** ស្ទុះទៅឱប **ម៉ានយ៉ាន** យំទាំងពីនាក់"នេះគឺបុណ្យ ព្រេង យើង " ។

នាយ **រ៉េភ** និយាយថា "ខ្ញុំចេញទៅលក់ត្រីសិន"

## ជំពូកទី១១

យើងមិនបាច់ឆ្ងល់ទេ **ម៉ានយ៉ាន** នឹង **សូផាត** បានជួបគ្នាក្នុងវេលា ពេលនោះឯង ។ អ្នកទាំងពីរមូលមេត្រីជាគូឥតអ្នកណាមួយដឹង ក្រៅពីនាយ **រ៉េភ** នេសាទត្រី ។

ឱ ! ប្រសិនណាជាលោកអធិបតីដឹងដំណឹងវិញ ?

ឱ ! ប្រសិនណា សំណាង ដឹងដំណឹងវិញ ?

ថ្ងៃមួយ **សូផាត** និយាយទៅ **ម៉ានយ៉ាន** ថា "អូនបង ! ស្រុកច្បារ អំពៅនៅនឹងច្រមុះស្រុកភ្នំពេញ គេថាដីរស្លាប់យកចង្កេរមកបាំងឯណាជិត បើ យើងមិនជៀសចេញពីទីនេះ បើមិនយូរក៏ឆាប់គេនឹងដឹងដំណឹងពីយើង គួរយើង ចេញពីទីនេះទៅ ។

-ខ្លួនប្អូនជាស្រី តាមតែគំនិតបង ។

វេលាដែលនាយ **រ៉េត** មកពីនេសាទត្រី សូផាត និយាយប្រាប់ថា : "សម្លាញ់ ! សម្លាញ់មានគុណនឹងខ្ញុំណាស់ ប៉ុន្តែយើងនៅស្ថិតស្ថេរក្នុងស្រុកនេះ ទៀតមិនបាន ក្រុងភ្នំពេញនៅជិតបង្កើយ គេថាផ្លូវហើងវែង មាត់មនុស្សវែង ជាងផ្លូវទៅទៀត" យើងសូមលាសម្លាញ់នឹងចេញពីនេះ ។

នាយ **រ៉េត** បើកភ្នែកធំៗ "កុំអាលអញ្ជើញទៅណា ខ្ញុំចិញ្ចឹមសម្លាញ់ ឯងទាំងពីរនាក់មិនបានឬ ? ក្នុងរវាងមួយខែពីរទៀត ។ ខ្លាចអ្នកណា យើង សុខចិត្តស្រឡាញ់គ្នាហើយ គ្មានអ្វីធំជាងចិត្តទេ ឪពុក ម្តាយ ឱ្យមានប្តី ប្រពន្ធ មិនគាប់ចិត្ត ថ្ងៃក្រោយមិនមែនឪពុកទេ ដែលទទួលខុសត្រូវលើជីវិតយើងក្នុង មួយជាតិនេះ"

-សម្លាញ់និយាយនេះត្រូវម្យ៉ាងហើយ ប៉ុន្តែប្អូនសម្លាញ់ឯងនេះ មាន គេបានជូនឥវ៉ាន់ច្រើនណាស់ កាលដែលគេចូលដណ្តឹង ។ ឥវ៉ាន់នៅជាប់នឹងខ្លួន នាងផង បើគេដឹងថានាងរស់ជីវិតនៅជាមួយខ្ញុំ គេនឹងអូសអស់ជាមិនខាន គេ ប្តឹងចៅក្រមធ្វើទោសផង ។

នាយ **រ៉េត** ឈប់មួយស្របក់ ។

-សម្លាញ់គិតឃើញយ៉ាងដូចម្តេចស្រួល គិតទៅចុះ ។

លុះប៉ុន្មានថ្ងៃក្រោយមក **សូផាត** និង **ម៉ានយ៉ាន** នាំគ្នាទៅនៅក្នុង ស្រុកមួយឆ្ងាយបន្តិចពីទីរួមខេត្តស្វាយរៀង ។ សង្សារទាំងពីរព្រមព្រៀងគ្នា លក់ខ្សែមាស ខ្សែពេជ្រតូចៗ ទិញបានជាលំនៅ ជាដីស្រែ វេលាដែល សូផាត នៅកាប់គាស់ដីដាំដំណាំ ម៉ានយ៉ាន នៅផ្ទះថែរក្សាទ្រព្យសម្បត្តិ មើលខុសត្រូវ ក្នុងផ្ទះ ក្រៅផ្ទះ ដាំបាយធ្វើម្ហូប ។

អ្នកទាំងពីរដូចលលកញីឈ្មោល ស្រឡាញ់គ្នាហាក់ថ្លើមមួយ ប្រម៉ាត់ មួយ ។

អ្នកស្រែនៅក្នុងភូមិ មានផ្ទះនៅជិតខាង សឹងតែស្រឡាញ់រាប់អាន អ្នកចំណូលទាំងពីរនាក់នេះណាស់ ។

អ្នកទាំងអស់ស្មានថាជាប្តីប្រពន្ធពេញច្បាប់ ។

ឥតអ្នកណាដឹងឫសកែវបន្តិចសោះ ។

ខែជេស្ឋចូលមកដល់ ទឹកភ្លៀងធ្លាក់កាន់តែច្រើន អ្នកធ្វើស្រែរាល់គ្នា មមាញឹករាស់ដីយ៉ាងមាំទាំ ។

**សូផាត** ក៏ធ្វើដូចអ្នកទាំងពួងដែរ ប៉ុន្តែវេលានឹងព្រួសស្រូវ ស្រាប់តែ ពិនិត្យទៅឃើញថាខ្វះពូជស្រូវ ក៏និយាយទៅសង្សារថា "កែវបង ! ឥឡូវយើង ត្រូវការទិញពូជស្រូវទៀត ទើបគ្រប់គ្រាន់ តើយើងត្រូវធ្វើដូចម្តេច បើយើង មានប្រាក់ យើងទិញផ្ទះទិញដី ទិញរបស់ប្រើប្រាស់ជិតអស់ទៅហើយ គ្រឿង មាសពេជ្រតូចៗ យើងលក់គ្មានសល់ ។

-អ្នកបង ! ចិញ្ចៀនពេជ្រខ្ញុំមានតម្លៃថ្លៃណាស់ ក្នុងស្រុកនេះឥតមាន អ្នកណាហ៊ានទិញទេ អ្នកបងប្រថុយអញ្ជើញទៅភ្នំពេញ យកចិញ្ចៀននេះទៅ លក់ ឱ្យដល់ហាងក្លិង្គ ដែលនៅមាត់ទន្លេ ធ្លាប់ទទួលទិញមាសពេជ្រ ។

-ពូជស្រូវមិនថ្លៃប៉ុន្មានទេអូន !

-ចាំទេ ខ្ញុំចង់បានប្រាក់ឱ្យច្រើន នឹងចាយវាយទៅថ្ងៃក្រោយទៀត អ្នកបងអញ្ជើញទៅភ្នំពេញចុះ ប៉ុន្តែប្រយ័ត្នបន្តិច ។

បើដូច្នោះ ស្អែកបងនឹងចេញទៅ ។

លុះព្រលឹមឡើង **សូផាត** នឹងធ្វើដំណើរចាកចេញពីដួងជីវិតអ្នក ដោយអ្នកមិនចង់ឃ្លាតឃ្លាចេញឆ្ងាយសោះ អ្នកមានចិត្តអាឡោះអាល័យក្រៃ ពេកណាស់ ។ អ្នកនិយាយថា "អូន ! បងដែលធ្វើដំណើរនេះ តោងធ្វើច្រើន ដំណាក់ណាស់ ពីព្រោះបងត្រូវជៀសវាងស្រុកប្រជុំជន បងនឹងដើរទៅឡើង ឡានឱ្យហួសពីទីផ្សារ បងនឹងចុះពីលើឡានមុននឹងដល់ស្ពាន "បាសាក់" គិតទៅ ដំណើរបងយូរណាស់ យ៉ាងតិចបួន ឬប្រាំថ្ងៃ ដូច្នេះបើប្រសិនណារោគាព្យាធិ អ្វីមកបៀតបៀនដល់អូន ចូរប្អូនរកពេទ្យចេះវិជ្ជាបារាំងមើលជំងឺនាង កុំ បណ្តែតបណ្តោយឱ្យគ្រូផ្ទេសផ្តាសមើល ម្យ៉ាងទៀតមនុស្សចាស់ៗក្នុងភូមិ ចូរ ប្អូនខំយកចិត្ត បើមានអាសន្នអ្វីៗ អ្នកនេះឯងហើយជាញាតិរបស់យើង ។

នាង **ម៉ានយ៉ាន** ស្ទុះទៅឱបអ្នកប្រុសថ្ងៃ : "ចា អ្នកបង!"

អ្នកទាំងពីរឈរប្រឱបគ្នា ។

នាង **ម៉ានយ៉ាន** ផ្តេកក្បាលទៅលើទ្រូងសង្សារ អ្នកប្រុសជ្រងសក់ នាង ចាប់ទាញអង្អែលសក់ អង្អែលថ្ពាល់... មានទឹកភ្នែករលីងរលោងរាល់គ្នា ។ នាង **ម៉ានយ៉ាន** ស្រដីទាំងទង្គឹះអួលក្នុងចិត្ត : "អ្នកបងអញ្ជើញទៅប្រយ័ត្ន តាមផ្លូវឱ្យមែនទែន "

អ្នកទាំងពីររមិនចង់ឃ្លាតឃ្លាពីគ្នាសោះ ប៉ុន្តែវាទាស់តែត្រឹមទ័ល ។

បន្ទិច **សុផាត** ប្រដាប់ដោយខោអាវដូចអ្នកស្រែធម្មតា គឺពាក់មួក ខ្មៅហាមធំអាវចិន ខោចិនខ្មៅយ៉ាងជំនុំ ស្ពាយបង្វិចតូចមួយដើររបៀមបារី សង្កែ កាន់ជន្លួញនៅដៃ ។ នាង **ម៉ានយ៉ាន** ជូនដំណើរសង្សារ លុះត្រាតែហួស វាលវែងមួយទើបត្រឡប់មកផ្ទះវិញ ។ ទេ នាងមិនទាន់ត្រឡប់មកភ្លាមទេ នាងឈរក្រោមដើមត្នោតមើលទៅប្តីដែលដើរកាន់តែឆ្ងាយទៅៗ លឹមៗ បន្តិច លិចបាត់ក្នុងគម្ពោតព្រៃ នាងស្រក់ទឹកភ្នែក អាណិតប្រុសកល្យាណ លុះវិល ថ្កានមកផ្ទះវិញនៅស្ងប់ស្ងាត់ ត្រមោចឯកាតែម្នាក់ឯង ។ នាងអុជធូបបីសរសៃ សំពះបន់ គុណបុណ្យឱ្យលោកជួយប្តីនាង ។

និយាយពី **សុផាត** វិញ អ្នកដើរបណ្តើរងាកមើលមកប្រពន្ធបណ្តើរ លុះត្រាតែឆ្ងាយទៅ ងាកមើលមិនឃើញ ។ អ្នកនឹកមកដល់ប្រពន្ធនៅតែម្នាក់ ឯងអ្នកនឹកពីក្តីកម្សត់កម្រនឹងអ្នក អ្នកអស់កម្លាំងនឹងឈានជើងដើរតទៅទៀត សឹងតែពុំបាន ។

បន្តិចអ្នកដើរមកដល់ផ្លូវថ្នល់ ចម្ងាយពីផ្សារស្វាយរៀង ចំនួនដប់ គីឡូម៉ែត្រ ។ ឡានមួយមកពីព្រៃនគរបើកមកដល់ **សុផាត** ហៅឈប់ ទើប ឡើងជិះ ។

ឡានបើកផុតទីព្រែកអ្នកលឿងបន្តិច គោមួយចេញពីវាលស្រែមក អ្នកបើកឡានស្មានថាជាគោនៅស្ងៀមក៏មិនបង្អង់ម៉ាស៊ីន គោនោះរត់កាត់ផ្លូវ មួយរំពេចទង្គិចនឹងឡាន ឡានកិនគោ គោស្លាប់ ឡានក្រឡាប់ ភ្លាម ។

អ្នកជិះមានរបួសច្រើន ។

**សុផាត** សន្លប់មិនដឹងខ្លួន ។

គេយកអ្នកត្រូវរបួសទាំងអស់ទៅមន្ទីរព្យាបាលរោគ ។

នាង **ម៉ានយ៉ាន** នៅម្នាំងឯងឯខេត្តស្វាយរៀងនាងរព្ញកនឹកប្តីសព្វទិន ទិវារាត្រីមិនដែលដាច់ ចាំមើលផ្លូនប្តីក្រឃើញមកដល់ កើតមានបារម្ភខ្លាំង ។ ថ្ងៃមួយនាងឈឺចាប់ខ្លាំងក្នុងក្បាល ក្តៅខ្លួនញ័រចំប្រប់ ទាំងកាយបាយ ទឹក ចំណី ចំណុក នាងអាស្រ័យពុំបាន ។ ចាស់ៗនៅជិតខាងគេមកជួយរកថ្នាំឱ្យនាង ។

រកមិនដល់សោះ ជំងឺនាងនៅតែដដែល ។

នាងសួរមនុស្សចាស់ម្នាក់ "លោកតា ! នៅស្រុកយើងមានពេទ្យ បារាំងទេ ?

-មានចៅ ប៉ុន្តែតោងឡើងទៅផ្សារហើយ ។

-ចាំ ! ខ្ញុំទៅឱ្យគ្រូពេទ្យមើលរោគខ្ញុំ លោកតាអាណិតរកពឹងអ្នកណា ឱ្យគេទៅអញ្ជើញលោកគ្រូពេទ្យមកបានទេ ? "

-មានអីចៅ

នាងយកប្រាក់ពីហោប៉ៅអាវហុចជូនទៅលោកតាចាស់ : "នេះ សោ ហ៊ុយអ្នកទៅតាមពេទ្យ "

តាចាស់ក៏អញ្ជើញទៅបាត់ ។

ចំនួនប្រាំម៉ោងក្រោយមក គ្រូពេទ្យអញ្ជើញមកដល់ ។ គ្រូពេទ្យ អស្ចារ្យនឹងផ្ទះនាង **ម៉ានយ៉ាន** ដែលមិនមានសណ្ឋានដូចផ្ទះអ្នកស្រែទាំងពួង សោះ របៀបរៀបចំទាំងអស់ ជារបៀបយ៉ាងចំណានរបស់អ្នកក្រុងជាន់ខ្ពស់ ។ លុះឃើញមុខអ្នកជំងឺ គ្រូពេទ្យស្គាល់ជាក់ នឹកថា "នាងដែលរៀបការ និង **សំណាង** សម្លាញ់អញទេតើ !"

លុះពិនិត្យអាការរោគស្រេច គ្រូពេទ្យនិយាយថា "អ្នកជំងឺនេះខ្ញុំមើល មិនបានទេ ខ្ញុំនឹងបញ្ជូនអ្នកទៅភ្នំពេញ ឱ្យគ្រូពេទ្យមើល" ។

ចាំ ខ្ញុំមិនទៅភ្នំពេញទេ ខ្ញុំស៊ូមើលបន្តិច នៅទីនេះហើយ

-ទេ អ្នកមិនអញ្ជើញទៅមិនបានទេ ជំងឺនេះទុកយូរប្រាកដជាមិនបាន ។

ក្រោយមកនាងព្រមឱ្យគ្រូពេទ្យបញ្ជូននាងទៅភ្នំពេញ ។

នាងក៏អាស្រ័យមើលជំងឺនៅផ្ទះពេទ្យឯភ្នំពេញ ។

គ្រូពេទ្យសរសេរសំបុត្រមួយទៅ សំណាង ជាមិត្តរបស់ខ្លួន ប្រាប់ពី រឿងខ្លួនដែលបានប្រទះនាងនៅខេត្តស្វាយរៀង ពីខ្លួនប្រើឧបាយកលបញ្ជូននាង ទៅមន្ទីរព្យាបាលរោគឯភ្នំពេញ ។

លុះដឹងដំណឹងសព្វគ្រប់ហើយ សំណាង ញញឹមស្ងួតខាំមាត់ដោយមាន ចិត្តគុំគួន ខឹងនឹង **ម៉ានយ៉ាន** ជាច្រើន "មេនេះវាធ្វើពុតអាក្រក់ណាស់តើ"

ដំណឹងនេះ **សំណាង** ផ្សាយទៅឪពុក ម្តាយខ្លួនជ្រាបភ្លាម ។

ពេលម៉ោង ៥ កន្លះ **សំណាង** រៀបខ្លួនស្លៀកពាក់ស្រេច ទើបឡើង រទេះឡានបើកទៅផ្ទះពេទ្យ ។

លុះឡានបើកមកដល់មន្ទីរពេទ្យព្យាបាលរោគ **សំណាង** បញ្ឈប់ ឡានទើបលោតចុះដល់ដីមួយរំពេច ដើរតម្រង់ចូលទៅបន្ទប់ស្រីៗ ។ **សំណាង** អើតមើលពីគ្រែមួយទៅគ្រែមួយ មិនឃើញនាងសោះ ។ បន្តិចចោលកន្ទុយ ភ្នែកទៅកៀនជញ្ជាំង ស្រាប់តែឃើញនាង **ម៉ានយ៉ាន** អង្គុយត្របោមក្បាល នឹកមមៃទៅប្តី ។ **សំណាង** នឹកព្រួចថា "វាន់ុះហ្ន៎ ស្ទុះខ្មីឃ្មាតទៅជិត " យី ខ្ញុំ ស្មានតែស្លាប់បាត់ទៅហើយ ? ។

នាង **ម៉ានយ៉ាន** ឥតភ័យ "ខ្ញុំមានវិញ្ញាណតែសព្វថ្ងៃ ... "

**សំណាង** ខឹង ! "នាងស្រី ! កាលដែលខ្ញុំរៀបអាពាហ៍ពិពាហ៍ និង នាង ខ្ញុំចាយវាយមាសប្រាក់ច្រើនណាស់ "

-មិនមែនខ្ញុំបង្គាប់អ្នកឯងចាយវាយមាសប្រាក់ច្រើនទេ ។

-យ៉ាងហ្នឹងហើយ ប៉ុន្តែកាលដែលនាងឯងរត់ទៅ នាងឯងបានយក មាសពេជ្រខ្ញុំដោយទៅច្រើនណាស់ ។

-ខ្ញុំនឹងជូនអ្នកវិញមិនខាន ។

**សំណាង** គន់មើលទៅនាង វេលាដែលខឹង មានឈាមក្រហមពេញ ទាំងមុខស្រស់ស្រគាគួរឱ្យចេតនាពេកណាស់ សេចក្តីស្នេហារបស់ សំណាង ដែលរលត់ស្ងាត់សូន្យដរាបមកក៏ភ្ញាក់កម្រើកឡើងជាថ្មី ។

**សំណាង** បន្ទន់សម្លេង ធ្វើមុខប្រិមប្រិយ អូន ! បងមិនចង់បាន ប៉ុន្មានទេ មាសពេជ្រដែលបងជូននាងហើយ ចិត្តបងចងចាំនៅតែនឹងពៅ ។

-ចូរអ្នកភ្លេចខ្ញុំឱ្យជ្រះស្រឡះទៅ ។

-ទេអូន ! បងស៊ូស្លាប់ជាជាង

-ទេអ្នក!

**សំណាង** ខិតចូលកាន់តែជិត ។

**សុផាត** ដែលត្រូវគ្រោះជិះឡានក្រឡាប់ គេយកមកឱ្យដេកពេទ្យ អ្នកដេកនៅថ្នាក់ជាន់ខាងលើ ។ រាល់តែល្ងាចអ្នកតែងចុះមកដីដើរ ហើយទុក្ខ នឹករលឹកដល់ភរិយា ។ វេលាដែល **សំណាង** និយាយនឹង **ម៉ានយ៉ាន** អ្នក ស្តាប់សម្លេងប្រពន្ធអ្នកបាន អ្នកស្ទុះទៅជិតស្រាប់តែឃើញប្រុសម្នាក់កំពុងតែ អង្វរចិត្តនាង ។ **ម៉ានយ៉ាន** វេលាណាក្រឡេកឃើញប្តី នាងស្ទុះម្ទីម្ទាទៅឱបប្តី ដោយរលឹកពេកណាស់ ។ សំណាង ក្រញេងក្រញាងស្ទុះទៅដែរ ។

ប្រុសទាំងពីរឈរទល់មុខគ្នា ខាំមាត់តែសព្វខ្លួន ។

ឪពុកម្ដាយ **សំណាង** បានផ្សាយដំណឹងពី **ម៉ានយ៉ាន** ទៅលោក អធិបតីសេនា ។ ឧកញ៉ា **សួន** កាលណាលោកបានជ្រាបថា ម៉ានយ៉ាន គង់ជីវិត លោកប្រញិបប្រញាប់អញ្ជើញទៅមន្ទីរពេទ្យភ្លាម ។ លុះមកដល់បន្ទប់នាង **ម៉ានយ៉ាន** ស្រាប់តែក្រឡេកមើលទៅឃើញឈរជិត **សុផាត** កំពុងតែចង់ ប្រយុទ្ធ នឹង សំណាង ។



លោកត្រេកអរឥតឧបមា ស្ទុះប្រញិបប្រញាប់ **សុផាត! ម៉ាន យ៉ាន !**

អ្នកទាំងពីស្ទុះមកឱបបាទជើងលោក ។

លោកញញឹមមានប្រសាសន៍ថា "ក្រោក!"

អ្នកទាំងពីរធ្វើការបង្គាប់ ។

**សំណាង** នៅស្ងៀមឥតវាចាអ្វី ។

លោកអធិបតីសេនា **សួន** ចាប់ដៃ **សុផាត** ទាំងពីរ "កូនប្រុស ឯង ជាកូនបង្កើតអញនេះហើយឈ្មោះ **សួន** ពីដើមអញធ្វើបាល័ដ្ឋនៅ សិរីសោភ័ណ ... ឪពុកស្មានទថាជាអ្នកស្លាប់យូរណាស់មកហើយ !" ទើបលោកបែរមកចាប់ ស្មា **ម៉ានយ៉ាន** ទាំងពីរ "កូនស្រី ! ឪពុកស្មាន ថាជាកូនលង់ទឹកស្លាប់ ... "

**សុផាត** និង **ម៉ានយ៉ាន** ស្ទុះទៅឱបឪពុកជាថ្មីទៀតហូរទឹកភ្នែក សស្រាក់ ។

ឧកញ៉ា **សួន** អញ្ជើញទៅជិត **សំណាង** ទើបមានប្រសាសន៍ថា : នាង ! បណ្ណាការទាំងប៉ុន្មាន ដែលអ្នកបានជូនខ្ញុំ ខ្ញុំនឹងបង្វិលជូនទៅអ្នកវិញ ឱ្យ គ្រប់ចំនួន ខ្លួនអ្នកមិនមែនជាគូរព្រេង និងក្ខយប្រពន្ធខ្ញុំទេ នាង **ម៉ានយ៉ាន** មានចិត្តចេតនាតែលើកូនខ្ញុំនេះ លោកចង្អុល **សុផាត** ខ្ញុំនឹងផ្សំផ្គុំរៀបការអ្នក ទាំងពីរ ឱ្យបានគ្នាជាភរិយាស្វាមីតទៅ

**សំណាង** សំពះលាលោកឈ្ងោកមុខដើរចេញ ។

........................................................

........................................................

ប៉ុន្មានថ្ងៃក្រោយមក គេរៀបការ **សុផាត** និង **ម៉ានយ៉ាន** យ៉ាង អ៊ឹកធឹកគគ្រឹកគគ្រេង ។ ក្នុងបណ្ដាភ្ញៀវទាំងប៉ុន្មាន មេស្រុក **សុខ** នឹង នាយ **រ៉ែក** សើចក្អាកក្អាយជាងគេទាំងអស់ ។

~ចប់~